គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

សិក្ខាសាលាស្តីពីឧបករណ៍មិនបង្កទំនាស់

# ការវិភាគគម្រោងតាមរយៈ ឧបករណ៍ មិនបង្កទំនាស់

សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល

Partnerships for Sustainable Development for Cambodia

# សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល

## ការវិភាគគម្រោងតាមរយៈឧបករណ៍មិនបង្កទំនាស់

ប្រែសម្រួលពីសៀវភៅណែនាំគ្រូបណ្តុះបណ្តាល
ឧបករណ៍បង្កទំនាស់របស់អង្គការ ស៊ីឌីអេ (CDA)

ភ្នំពេញ

ខែកញ្ញា ឆ្នាំ២០១៩

# មាតិកា


**ការប្រើប្រាស់ពាក្យ** 1

**១. សាវតា និងមេរៀនរបស់ឧបករណ៍មិនបង្កទំនាស់** 5

១.១ ប្រវត្តិឧបករណ៍មិនបង្កទំនាស់ 6

១.២ តើឧបករណ៍មិនបង្កទំនាស់គឺជាអ្វី? 12

១.៣ ការយកចិត្តទុកដាក់នឹងទំនាស់ និង ការកសាងសន្តិភាព 13

១.៤ មេរៀនចំនួន៦របស់ឧបករណ៍មិនបង្កទំនាស់ 15

**២. ៧ ជំហាននៃដំណើរការឧបករណ៍មិនបង្កទំនាស់** 18

**ជំហានទី១៖ ការវិភាគបរិបទ** 19

**ជំហានទី២ និង ទី៣៖ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់** 20

ប្រភេទនៃការវិភាគ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ 21

ប្រព័ន្ធ និង ស្ថាប័ន 21

ឥរិយាបថ និង សកម្មភាព 21

គុណតម្លៃ និង ផលប្រយោជន៍ 22

បទពិសោធន៍ 23

និមិត្តរូប និង ព្រឹត្តិការណ៍ 24

ការពិចារណាក្នុងការវិភាគបរិបទ 24

កម្រិតនៃការវិភាគ 26

កត្តាបែកបាក់/កត្តាផ្សារភ្ជាប់ និង ការត្រួតពិនិត្យ វាយតម្លៃ ការរៀនសូត្រ 28

**ជំហានទី៤៖ ការវិភាគកម្មវិធី** 29

ព័ត៌មានលម្អិតសំខាន់ៗនៃការរៀបចំកម្មវិធី 30

តើយើងកំពុងធ្វើការជាមួយនរណា? 30

តើយើងនឹងធ្វើការនៅកន្លែងណា? 30

តើយើងកំពុងធ្វើអ្វី? 31

តើនៅពេលណាដែលអន្តរាគមន៍របស់យើងនឹងកើតឡើង? 31

ហេតុអ្វី និងដោយវិធីណា? 32

កត្តាគម្រាមកំហែង 33

សកម្មភាព 33

ការវិភាគ និងការពិនិត្យតាមដានកម្មវិធី វាយតម្លៃ និងការរៀនសូត្រ 33

**ជំហានទី៥៖ សណ្ឋានផលជះ** ( Parterns of Impact ) 34
ផលជះលើការផ្ទេរធនធាន/សកម្មភាព 34
១. ឥទ្ធិពលនៃការបង្វែរធនធាន 35
២. ឥទ្ធិពលទីផ្សារ 36
៣. ឥទ្ធិពលនៃការចែកចាយ 36
៤. ឥទ្ធិពលនៃការជំនួស 37
៥. ឥទ្ធិពលទទួលស្គាល់ 37
សណ្ឋានអាកប្បកិរិយាជាវិជ្ជមាន 38
សារបង្កប់ន័យក្រមសីលធម៌ / អាកប្បកិរិយា 40
១. ការគោរព 40
២. គណនេយ្យភាព/ការទទួលខុសត្រូវ 41
៣.ភាពត្រឹមត្រូវ / ស្មើភាព 41
៤. តម្លាភាព 42
ការរៀបចំកម្មវិធី 43
ការយល់ដឹងអំពីផលជះ 43
ការស្វែងរកជម្រើស 43
ការធ្វើសកម្មភាព (សណ្ឋានផលជះ) 43
សណ្ឋានផលជះ និងការត្រួតពិនិត្យ វាយតម្លៃ និងការរៀនសូត្រ 44
**ជំហានទី៦ និង ទី៧៖ ការបង្កើតជម្រើស និង ការរៀបចំកម្មវិធីឡើងវិញ** 45
ការបង្កើតជម្រើសកម្មវិធី 46
**សកម្មភាព** 48
ការពិនិត្យតាមដាន ការវាយតម្លៃ និងរៀនសូត្រ ព្រមទាំងជម្រើស 49

# ការប្រើប្រាស់ពាក្យ

| ល.រ | ខ្មែរ / English | ការពន្យល់ពាក្យ |
|---|---|---|
| ១ | **ឥរិយាបថ និង សកម្មភាព**<br>Attitude & Action | សំដៅទៅលើអ្វីដែលមនុស្សនិយាយ និងអ្វីដែលមនុស្សធ្វើ។ មនុស្សអាចជម្រុញកត្តាផ្សារភ្ជាប់ ឬ កត្តាបែកបាក់ តាមរយៈសកម្មភាពរបស់ពួកគេ។ |
| ២ | **ទំនាស់**<br>Conflict | វាជាភាពខុសគ្នានៃគំនិតយោបល់ ឬ ការយល់ឃើញ។ នៅក្នុងក្រុមមួយ ដែលមានសមាជិកមាន៖ ប្រវត្តិ ជំនាញ បទពិសោធន៍ខុសៗគ្នា។ សម្រាប់ក្រុមមួយ ទំនាស់អាចវិជ្ជមាន ឬ អវិជ្ជមាន។<br>ដើម្បីអាចក្លាយជាទំនាស់បាន លុះត្រាតែ៖<br>• ទំនាស់ជាលក្ខខណ្ឌធម្មជាតិនៃទំនាក់ទំនងរបស់មនុស្ស<br>• មានភាគីពាក់ព័ន្ធយ៉ាងតិចពីរ<br>• មានភាគីយ៉ាងហោចណាស់មួយ មានអារម្មណ៍ថា ផលប្រយោជន៍របស់ខ្លួនត្រូវបានរារាំង<br>• មានភាគីយ៉ាងហោចណាស់មួយលើកឡើងពីបញ្ហា |
| ៣ | **ភាពសកម្មនៃទំនាស់**<br>Conflict Dynamics | “ **ភាពសកម្ម**-Dynamics ” វាជាដំណើរការ ឬ ប្រព័ន្ធ ដែលនាំឲ្យ មានការផ្លាស់ប្តូរ។ ភាពសកម្មនៃទំនាស់ គឺជាដំណើរការ ឬ ទំនាក់ទំនងនៃទំនាស់ដែលមាននៅក្នុងបរិបទ។ |
| ៤ | **ការយកចិត្តទុកដាក់នឹងទំនាស់**<br>Conflict Sensitivity | វាគឺជាលទ្ធភាពរបស់អង្គការមួយ ក្នុងការយល់ដឹងពីបរិបទដែលខ្លួនកំពុងធ្វើការ យល់ដឹងអំពីរបៀប ដែលសេចក្តីលម្អិត (សកម្មភាព និង ដំណើរការ) នៃការធ្វើអន្តរាគមន៍របស់ខ្លួន មានទំនាក់ទំនងទៅនឹងបរិបទ និងធ្វើសកម្មភាពផ្អែកលើការយល់ដឹងនេះ ដើម្បីកាត់បន្ថយផលជះអវិជ្ជមានឲ្យដល់កម្រិតអប្បបរមា នៃការធ្វើអន្តរាគមន៍របស់ខ្លួននៅក្នុងបរិបទ និងបង្កើនផលជះវិជ្ជមានឲ្យដល់កម្រិតអតិបរមា។ |
| ៥ | **កត្តាផ្សារភ្ជាប់**<br>Connector | វានាំមនុស្សឲ្យមកនៅជាមួយគ្នា ទោះបីជាពួកគេមានភាពខុសគ្នាក៏ដោយ។ ហើយវាអាចកាត់បន្ថយភាពសង្ស័យ ការមិនទុកចិត្ត និង វិសមភាពក្នុងសង្គម។ |
| ៦ | **បរិបទ**<br>Context | មានកិច្ចការសំខាន់ៗ ៣ ក្នុងការស្វែងយល់ពីបរិបទ៖ |

| | | |
|---|---|---|
| | | ១. កំណត់ធាតុផ្សំនៃតំបន់អនុវត្តកម្មវិធីសម្រាប់ការវិភាគបរិបទ<br>២. កំណត់តួអង្គក្នុងបរិបទ<br>៣. កំណត់ទំនាស់រវាងក្រុមនិងក្រុម ដែលបង្កហិង្សា ឬ មានគ្រោះថ្នាក់ និង អាចក្លាយទៅជាអំពើហិង្សា។ |
| ៧ | **ឥទ្ធិពលនៃការបង្វែរធនធាន**<br>Deviation Effect | ការបង្វែរ គឺជាការប្រើប្រាស់ធនធាន ដើម្បីគោលបំណងផ្សេង ក្រៅពីគោលបំណងដើមរបស់គម្រោង/កម្មវិធី។ ការបង្វែរភាគច្រើន ត្រូវបានប្រើប្រាស់ដើម្បីសំដៅទៅដល់ពាក្យ « **ចោរ** »។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចស្រម៉ៃឃើញថាការបង្វែរមានឥទ្ធិពលវិជ្ជមានផងដែរ។ |
| ៨ | **ឥទ្ធិពលនៃការចែកចាយ**<br>Distribution Effect | ការចែកចាយ គឺជារបៀបដែលធនធានត្រូវបានចែកចាយចេញទៅ |
| ៩ | **កត្តាបែកបាក់**<br>Divider | វាបង្កើនភាពតានតឹង ការទាស់ទែងគ្នា ឬ សមត្ថភាពបង្កឲ្យមានហិង្សា ឬសង្គ្រាមរវាងក្រុមមនុស្ស។<br>ហើយវាក៏អាចបង្កើនភាពសង្ស័យ ការមិនទុកចិត្ត ឬ វិសមភាពក្នុងសង្គម។ |
| ១០ | **ឧបករណ៍មិនបង្កទំនាស់**<br>Do No Harm | គឺជាឧបករណ៍មួយ ប្រើសម្រាប់អនុវត្តការយកចិត្តទុកដាក់នឹងទំនាស់ នៅក្នុងគោលនយោបាយ និងកម្មវិធីផ្តល់ជំនួយ ឬ អនុវត្តគម្រោង |
| ១១ | **បទពិសោធន៍**<br>Experience | **បទពិសោធន៍** គឺជាកត្តារឹងមាំមួយរបស់ កត្តាផ្សាភ្ជាប់ ឬ កត្តាបែកបាក់។ បទពិសោធន៍រួម ឬ ដូចគ្នាអាចបង្រួបបង្រួមក្រុមមនុស្សខុសៗគ្នាបាន។ បទពិសោធន៍ខុសៗគ្នានៃហេតុការណ៍មួយ អាចបង្កើតការយល់ឃើញខុសៗគ្នា និងការបែកបាក់ក្នុងសង្គម។ |
| ១២ | **ទំនាស់**<br>Harm | **"ទំនាស់-Harm"** យើងចង់ប្រើភាសាជាក់លាក់ថា *"**ផលជះអវិជ្ជមាន** លើកត្តាផ្សាភ្ជាប់រវាង ក្រុម ក និង ក្រុម ខ" ឬ "**ផលជះវិជ្ជមាន** លើកត្តាបែកបាក់រវាង ក្រុម គ និង ក្រុមឃ"*។ |
| ១៣ | **ផលជះ**<br>Impact | ផលជះអាចមាន ទាំង វិជ្ជមាន និង អវិជ្ជមាន លើបរិបទ |
| ១៤ | **សារបង្កប់ន័យ (ក្រមសីលធម៌)**<br>Implicit Ethical Messages | គឺជាសារដែលយើងបញ្ជូនចេញដោយចេតនា ឬ ដោយអចេតនាតាមរយៈសកម្មភាពរបស់យើង អត្តចរិត ឬ តាមរយៈបែបបទជីវិត។ អ្នកដែលទទួលបានសារទាំងនោះ ប្រហែល |

| | | |
|---|---|---|
| | | យល់ឃើញថា អត្ថន័យដែលមានជាប់ជាមួយសារទាំងនោះ គាំទ្រ ឬ ប្រឆាំងនឹងអត្ថន័យដើមដែលយើងចង់បញ្ជូនឲ្យគាត់។<br>គេអាចសង្កេតឃើញមានឥទ្ធិពលបួនយ៉ាង នៅពេលសារ បង្កប់ន័យក្រមសីលធម៌ត្រូវបានបញ្ជូន (ភាគច្រើនគឺដោយ អចេតនា) តាមរយៈបុគ្គលិកកម្មវិធីជំនួយ ឬអង្គការរបស់ពួក គេ និងដែលត្រូវបានទទួលយកនៅក្នុងបរិបទគម្រោង។ |
| ១៥ | **អន្តរាគមន៍**<br>Intervention | អន្តរាគមន៍ គឺជារបៀប និង ដំណើរការ (សេចក្តីលម្អិត) របស់ សកម្មភាពមួយ ឬ ច្រើន។ |
| ១៦ | **ឥទ្ធិពលទទួលស្គាល់/ស្របច្បាប់**<br>Legitimacy Effect | វាជាការប្រគល់សិទ្ធិអំណាច ការផ្តល់នូវការគោរព ការធ្វើឲ្យ អ្វីមួយត្រឹមត្រូវតាមលក្ខណៈផ្លូវច្បាប់ |
| ១៧ | **ឥទ្ធិពលទីផ្សារ**<br>Market Effect | ឥទ្ធិពលទីផ្សារកើតឡើង នៅពេលមានការផ្ទេរធនធាន |
| ១៨ | **សណ្ឋាន**<br>Pattern | គឺជារបៀបដែលរឿងរ៉ាវផ្សេងៗ សកម្មភាព ឬ អាកប្បកិរិយា ត្រូវបានចម្លងឡើងវិញ និង របៀបដែលពួកវាបង្កើតបានជា ឥទ្ធិពល។<br>យើងដឹងថា សណ្ឋានមួយអាចកើតមាននៅពេលដែលយើង សង្កេតឃើញ ឬ ជួបប្រទះអ្វីមួយដែលកើតឡើងនៅក្នុង របៀបដែលស្រដៀងទៅនឹងព្រឹត្តិការណ៍ សកម្មភាព អាកប្បកិរិយាផ្សេងទៀតជាដើម ដែលយើងធ្លាប់ដឹងរួចមក ហើយតាមរយៈការសង្កេត ឬ បទពិសោធន៍។ |
| ១៩ | **ការផ្ទេរធនធាន**<br>Resource Transfer | វាអាចមានឥទ្ធិពលដែលបានគ្រោងទុក ឬ មិនបានគ្រោងទុក ព្រមទាំងឥទ្ធិពលវិជ្ជមាន ឬ អវិជ្ជមានលើអ្នកទទួលផល ឬ នៅក្នុងបរិបទនៃការអនុវត្តកម្មវិធី |
| ២០ | **ឥទ្ធិពលនៃការជំនួស**<br>Substitution Effect | ការជំនួសមានន័យថា ការជំនួសអ្វីមួយ ដោយអ្វីមួយផ្សេង ទៀត ឬជំនួសអ្នកណាម្នាក់ដោយអ្នកណាម្នាក់ទៀត។<br>នៅក្នុងបរិបទគម្រោង ការជំនួសកើតឡើងនៅពេលដែល អង្គការមិនមែនរដ្ឋាភិបាល បានផ្តល់នូវសេវាកម្មអ្វីមួយ ដែល សេវាកម្មនោះគួរតែត្រូវផ្តល់ដោយរាជរដ្ឋាភិបាលទៅវិញ។ |

| | | |
|---|---|---|
| ២១ | **និមិត្តរូប និងព្រឹត្តិការណ៍**<br>Symbol & Occasion | **និមិត្តរូប** គឺជាតំណាងនៃអ្វីមួយដែលធំធេង ដូចជា៖ ទង់ជាតិតំណាងឱ្យប្រទេសមួយ ឬ ចលនាមួយ ពណ៌តំណាងឱ្យក្រុមមួយ ការដាក់ឈ្មោះផ្លូវដោយប្រើឈ្មោះវីរបុរស តំណាងឱ្យហេតុការណ៍ប្រវត្តិសាស្ត្រណាមួយ។<br>**ព្រឹត្តិការណ៍** ប្រមូលផ្តុំមនុស្សដើម្បីអបអរ កាន់ទុក្ខ ចងចាំ ឬប្រកួតប្រជែងគ្នា។ **និមិត្តរូប និង ព្រឹត្តិការណ៍**ទាំងនេះ អាចបង្រួបបង្រួមក្រុមមនុស្ស ឬ បំបែកបំបាក់ពួកគេ។ |
| ២២ | **ប្រព័ន្ធ និងស្ថាប័ន**<br>System & Institute | **ប្រព័ន្ធ និង ស្ថាប័ន** អាចមានលក្ខណៈបរិយាបន្ន ឬផ្តាច់មុខ ហើយអាចស្របច្បាប់សម្រាប់ទាំងអស់គ្នា ឬ សម្រាប់តែក្រុមមនុស្សខ្លះ។ សង្គមមួយដំណើរការបានតាមរយៈ **ប្រព័ន្ធ** និង ចាត់ចែងការគ្រប់គ្រងតាមរយៈ **ស្ថាប័ន**។ រចនាសម្ព័ន្ធទាំងនេះ អាចប្រើប្រាស់ជាកំលាំងប្រកបដោយថាមពល ដែលអាចជួយផ្សាភ្ជាប់ក្រុមមនុស្ស ឬ ជម្រុញឲ្យមានភាពខុសគ្នាធ្វើឱ្យពួកគេបែកបាក់គ្នា។ |
| ២៣ | **គុណតម្លៃ និងផលប្រយោជន៍**<br>Value & Interest | **គុណតម្លៃ និង ផលប្រយោជន៍** គឺជាអ្វីដែលមានសារៈសំខាន់សម្រាប់មនុស្សរួមមាន៖ ក្តីកង្វល់ គោលការណ៍ និងស្តង់ដាររបស់ពួកគេ។ **គុណតម្លៃ និង ផលប្រយោជន៍រួម** ផ្សាភ្ជាប់មនុស្ស **តែគុណតម្លៃខុសៗគ្នា** ឬ ការប្រកួតប្រជែងផលប្រយោជន៍ ធ្វើឲ្យពួកគេបែកបាក់គ្នា។ |

# ១. សាវតា និងមេរៀនរបស់ឧបករណ៍មិនបង្កទំនាស់

សិក្ខាសាលាណែនាំស្តីពី **ឧបករណ៍មិនបង្កទំនាស់** រៀបចំឡើងដោយផ្អែកលើឯកសារភស្តុតាងដែលទទួលបានពីបរិបទផ្សេងៗជាច្រើន ដោយបង្ហាញពីសាវតានៃការអនុវត្តឧបករណ៍មិនបង្កទំនាស់ និងវិធីសាស្ត្រប្រមូលភស្តុតាងទាំងនេះ។

មេរៀននេះ ចាប់ផ្តើមជាមួយនឹងកិច្ចស្វាគមន៍របស់គ្រូបណ្តុះបណ្តាល និងការណែនាំខ្លួនរបស់សិក្ខាកាម ព្រមទាំងបង្ហាញរបៀបវារៈលម្អិតរបស់សិក្ខាសាលា។ បន្ទាប់មក គ្រូបណ្តុះបណ្តាលធ្វើការពិភាក្សា និងបង្ហាញពី សាវតា និង វិធីសាស្ត្រនៃឧបករណ៍មិនបង្កទំនាស់ ហើយបញ្ចប់ដោយការបង្ហាញអំពីមេរៀនទាំង៦ និងក្របខ័ណ្ឌឧបករណ៍មិនបង្កទំនាស់។

## ខ្លឹមសារមេរៀន៖ វិធីសាស្ត្ររបស់ អង្គការ ស៊ីឌីអេ (CDA)

ស៊ីឌីអេ គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញតូចមួយ ដែលមានមូលដ្ឋាននៅទីក្រុង ខេមប្រីដ រដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក។ ស៊ីឌីអេ គឺជាអង្គការរៀនសូត្រមួយ ដែលយកចិត្តទុកដាក់ក្នុងការជួយដល់ស្ថាប័នអន្តរជាតិនានា (អង្គការមនុស្សធម៌ អភិវឌ្ឍន៍ កសាងសន្តិភាព និងសាជីវកម្ម...) ដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពរបស់ស្ថាប័នទាំងនោះ ក្នុងការជួយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ។ វិធីសាស្ត្ររបស់អង្គការ ស៊ីឌីអេ ហៅថា **វិធីសាស្ត្ររៀនសូត្ររួមគ្នា** (Collaborative Learning Menthod)។

**វិធីសាស្ត្ររៀនសូត្ររួមគ្នា** ចាប់ផ្តើមជាមួយនឹងករណីសិក្សា។ ពួកគេបានធ្វើការសិក្សាស្វែងយល់ពីស្ថានភាព បញ្ហាប្រឈមដែលជួបប្រទះ និងរបៀបដែលពួកគេព្យាយាមដើម្បីជម្នះបញ្ហាប្រឈមទាំងនេះ ព្រមទាំងវិធីដែលពួកគេទទួលបានជោគជ័យ ឬ វិធីដែលធ្វើឲ្យពួកគេបរាជ័យ ហើយនិងរបៀប ឬ វិធីសាស្ត្រជាច្រើនទៀតដែលពួកគេបានសាកល្បងធ្វើ។ ករណីសិក្សាទាំងនេះ បានដាក់បញ្ចូលគ្នានៅក្នុងការប្រឹក្សាយោបល់ដែលរួមមាន អ្នកសរសេរករណីសិក្សា ម្ចាស់ករណីសិក្សា និង អ្នកអនុវត្តជាច្រើនទៀត ។ ក្នុងដំណើរការប្រឹក្សាយោបល់ សណ្ឋានទូទៅមួយបានបង្កើតចេញពីករណីសិក្សាទាំងនេះ។

ដំណាក់កាលទី២ គឺជាការផ្តល់យោបល់ត្រលប់ ។ សណ្ឋានទូទៅ និង មេរៀនទទួលបានពីករណីសិក្សា បានបង្ហាញដល់អ្នកតំណាងមកពីអង្គការជាច្រើន ដែលធ្វើសកម្មភាពផ្ទាល់នៅតាមមូលដ្ឋាន។ អង្គការអនុវត្តផ្ទាល់ បានធ្វើការប្រៀបធៀបសណ្ឋានទាំងនេះ ជាមួយនឹងបទពិសោធន៍ផ្ទាល់របស់ខ្លួន ដើម្បីកំណត់ថា តើសណ្ឋាន និង មេរៀនដែលទទួលបានពីករណីសិក្សាទាំងនេះត្រឹមត្រូវឬទេ? ក្នុងដំណាក់កាលយោបល់ត្រលប់នេះ ចំណុចមិនត្រឹមត្រូវ ត្រូវបានយកចេញ។ ប្រហែលមួយភាគបីនៃអ្វីដែលទទួលបានពីករណីសិក្សា ត្រូវបានដកចេញក្នុងកំឡុងពេលផ្តល់យោបល់ស្តីពីឧបករណ៍មិនបង្កទំនាស់។ ប្រការនេះហើយដែលធ្វើឲ្យដំណាក់កាលផ្តល់យោបល់ត្រលប់មានសារៈសំខាន់។ ក្នុងដំណើរការនេះ យើងបានស្វែងយល់អំពីផ្នែកមួយចំនួនក្នុងករណីសិក្សា ដែលបានកើតឡើងជាឧប្បត្តិហេតុ ជាការយល់ឃើញទូទៅ ឬ ជាភាពលម្អៀងរបស់អ្នកសរសេរករណីសិក្សា។

អ្វីដែលនៅសល់ត្រូវបានបញ្ជាក់ និង អះអាងថាល្អសម្រាប់ការសិក្សា និងធ្វើការចែករំលែកសម្រាប់ការរៀនសូត្របន្ថែម។

ដំណាក់កាលទីបីគឺជាការអនុវត្ត។ អង្គការ ស៊ីឌីអេ យកអ្វីដែលជាមេរៀនទទួលបាន ទៅធ្វើការអនុវត្ត។ ការរៀនសូត្រអាចមានប្រយោជន៍ទៅបាន លុះត្រាតែវាត្រូវបានយកមកប្រើប្រាស់ ។ អង្គការ ស៊ីឌីអេ បានបន្តរៀនសូត្រអំពីរបៀបប្រើប្រាស់ឧបករណ៍មិនបង្កទំនាស់ ដើម្បីធ្វើវាឲ្យកាន់តែប្រសើរឡើង តាមរយៈការអនុវត្តមេរៀនទាំងនោះ។

ភាគច្រើននៃករណីសិក្សារបស់អង្គការ ស៊ីឌីអេ និង របាយការណ៍ទស្សនកិច្ចតាមមូលដ្ឋានត្រូវបានបង្ហោះនៅលើគេហទំព័ររបស់អង្គការ ស៊ីឌីអេ គឺ www.cdacollaborative.org ។

## ១.១ ប្រវត្តិឧបករណ៍មិនបង្កទំនាស់

### ដំណាក់កាលករណីសិក្សា (១៩៩៤-១៩៩៦)

ឧបករណ៍មិនបង្កទំនាស់ បានចាប់ផ្តើមជាកម្មវិធី ឬ គម្រោងរៀនសូត្ររួមគ្នាមួយ ក្នុងឆ្នាំ១៩៩៤ ដើម្បីឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចជា៖ **តើគ្រប់ប្រភេទជំនួយទាំងអស់ គួរត្រូវផ្តល់តាមរបៀបណា? ដើម្បីជួយទៅដល់ប្រជាពលរដ្ឋមូលដ្ឋានមិនឲ្យពាក់ព័ន្ធនឹងទំនាស់ និងបង្កើតនូវជម្រើសជាលក្ខណៈប្រព័ន្ធសម្រាប់ដោះស្រាយបញ្ហា ឬ មូលហេតុដែលបង្កឲ្យមានទំនាស់ ជាជាងការផ្តល់ជំនួយដែលបង្កឲ្យមានទំនាស់ ឬ ធ្វើឲ្យទំនាស់កាន់តែធ្ងន់ធ្ងរឡើង?**។ កម្មវិធីនេះ បានចាប់ផ្តើមដោយផ្អែកលើការសង្កេត ហើយបានរកឃើញថាជំនួយមួយចំនួន ពិតជាបានចូលរួមចំណែកក្នុងសកម្មភាពទំនាស់នៅក្នុងបរិបទនៃការអនុវត្តកម្មវិធី/គម្រោង ។ សកម្មភាពទំនាស់នេះ ត្រូវបានសង្កេតឃើញ នៅក្នុងបរិបទជាច្រើននៅជុំវិញពិភពលោក ហើយអ្វីដែលបានបង្ហាញឲ្យកាន់តែច្បាស់នោះ គឺក្នុងព្រឹត្តិការណ៍នៅប្រទេស **រវ៉ាន់ដា** ក្នុងឆ្នាំ១៩៩៤។ អ្នកសិក្សា បានចាប់ផ្តើមពិនិត្យមើលពីរបៀប និង មូលហេតុ ដែលកម្មវិធីផ្តល់ជំនួយ បានជះឥទ្ធិពលដល់សកម្មភាពទំនាស់ រហូតឈានទៅដល់អំពើប្រល័យពូជសាសន៍ក្នុងប្រទេសនោះ។

**ព្រឹត្តិការណ៍នៅរ៉្វាន់ដា**



**ការសន្និដ្ឋាន**

ការសម្លាប់រង្គៀលនៅរ៉្វាន់ដា គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយដ៏អាក្រក់បំផុត ដែលក្នុងរយៈពេល ១០០ថ្ងៃ មានមនុស្សជាង ៨០០.០០០នាក់ត្រូវបានសម្លាប់។ សោកនាដកម្មនេះ បានកន្លងផុតទៅហើយក្តី ប៉ុន្តែប្រវត្តិសាស្ត្របានកត់ត្រាពីការឈឺចាប់ និងផលប៉ះពាល់ដែលបានកើតឡើង។

អង្គការ ស៊ី ឌី អេ បានផ្តួចផ្តើមគំនិតបង្កើតគម្រោងមួយ ដែលនៅពេលនោះមានឈ្មោះថា **សមត្ថភាពមូលដ្ឋានដើម្បីសន្តិភាព** (Local Capacity for Peace) ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីរបៀបដែលជំនួយមានទំនាក់ទំនងជាមួយសកម្មភាពទំនាស់។ ករណីសិក្សាចំនួន១៥ ត្រូវបានសរសេរនៅចន្លោះឆ្នាំ ១៩៩៤-១៩៩៦ ដើម្បីពិនិត្យមើលផលជះរបស់ជំនួយក្នុងតំបន់ទំនាស់ចំនួន១៤។ ករណីសិក្សាទាំងនេះ បានសរសេរក្នុងបរិបទទំនាស់ដ៏សកម្មដែលកំពុងបន្ត ព្រមទាំងបរិបទក្រោយទំនាស់ក្នុងស្ថានភាពអំពើហិង្សាកម្រិតទាប ប៉ុន្តែមានលក្ខណៈរ៉ាំរ៉ៃជាប្រព័ន្ធនៅតាមតំបន់ការងារ និងតំបន់រស់នៅ។

## *ឯកសារបោះពុម្ពផ្សាយក្នុងដំណាក់កាលករណីសិក្សា៖*


១. **Anderson, Mary B** ស្បៀងអាហារសម្រាប់ការងារសាងសង់លំនៅដ្ឋានឡើងវិញនៅក្នុង ខេត្តខាតឡុង ប្រទេសតាជីគីស្ថាន៖ គម្រោងរបស់អង្គការសហព័ន្ធសង្គ្រោះកុមារ ខែមករា ឆ្នាំ១៩៩៥។

២. **Anderson, Mary B** ជំនួយព្រះវិហារន័រវែស និងក្រុមប្រឹក្សាជនភៀសខ្លួនន័រវែស គម្រោងរបស់ប្រទេសអាហ្វហ្កានីស្ថាន/ប៉ាគីស្ថាន៖ ករណីសិក្សា ខែមករា ឆ្នាំ១៩៩៥។

៣. **Anderson, Mary B** ទំនាក់ទំនងទីក្រុងហ្សេរុយសាឡឹម៖ ស្ត្រីដែលបានចូលរួមក្នុងទំនាស់ ខែសីហា ឆ្នាំ១៩៩៥។

៤. **Bock, Joseph** គម្រោងសុខដុមនីយកម្មរបស់អង្គការ St. Xavier's Social Service Society ទីក្រុង Ahmedabad រដ្ឋ Gujarat ប្រទេសឥណ្ឌា ខែមករា ឆ្នាំ ១៩៩៥។

៥. **Gluck, Kenny** ជំនួយអន្តរជាតិសម្រាប់ជនស៊ីវិល៖ សង្គ្រាមស៊ីវិល Abkhaz-Georgian ខែមីនា ឆ្នាំ ១៩៩៥។

៦. **Halvorsen, Kate** កិច្ចប្រឹងប្រែងធ្វើសមាហរណកម្មឡើងវិញនៅក្នុងបរិបទក្រោយសង្គ្រាម៖ សកម្មភាពរបស់ក្រុមប្រឹក្សាជនភៀសខ្លួនដាណឺម៉ាក និង ក្រុមប្រឹក្សាជនភៀសខ្លួនន័រវែសក្នុងប្រទេសម៉ូហ្សំប៊ិក ខែកញ្ញា ឆ្នាំ១៩៩៥។

៧. **Halvorsen, Kate** មាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និង សេចក្តីថ្លៃថ្នូរ? សកម្មភាពធ្វើសមាហរណកម្មឡើងវិញ និង ស្តារនីតិសម្បទារបស់គណៈកម្មាធិការអន្តោប្រវេសន៍ កាតូលិកអន្តរជាតិក្នុងប្រទេសកម្ពុជា ខែតុលា ឆ្នាំ១៩៩៥។

៨. **Hansen, Greg SAWA**/ការអប់រំសម្រាប់សន្តិភាព៖ ការរួបរួមកុមារ និងយុវជនលីបង់ ក្នុងអំឡុងសង្គ្រាម ខែមិថុនា ឆ្នាំ១៩៩៥។

៩. **Holm-Pedersen, Helene** ការផ្សះផ្សាស្ថិតក្នុងកាកបាទក្រហមក្នុងស្រុកតាមរយៈកិច្ចសហប្រតិបត្តិការមុខងារ៖ សហព័ន្ធសង្គមកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមអន្តរជាតិក្នុងប្រទេស Bosnia Herzegovina ខែតុលា ឆ្នាំ១៩៩៥។

១០. **Jackson, Stephen** កម្មវិធីស្តារនីតិសម្បទាដែលត្រូវបានធ្វើសមាហរណកម្មរបស់អង្គការ Trocaire នៅតំបន់ Gedo នៅភាគនិរតីប្រទេសសូម៉ាលី ខែមករា ឆ្នាំ១៩៩៥។

១១. **Lyke, Susan និង Joseph Bock** គម្រោងសាកល្បង Orangi៖ វិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាល ទីក្រុងការ៉ាឈី ខែកញ្ញា ឆ្នាំ១៩៩៥។

១២. **Lent, Tom** ការជូនពរគឺជាអ្នកដែលបង្កើតលំហះ ការកសាងសន្តិភាព និងដំណើរការសន្តិភាពក្នុងស្ថានភាពដែលមានទំនាស់ ករណីសិក្សារបស់ប្រទេស ហ្គាតេម៉ាឡា ឆ្នាំ១៩៧៦-១៩៩៦ ខែមីនា ឆ្នាំ១៩៩៦។

១៣. Minear, Larry ការផ្សះផ្សាឆ្លងកាត់ព្រំដែន៖ បទពិសោធន៍ក្នុងប្រទេសក្រូអាស៊ី ខែមករា ឆ្នាំ១៩៩៥។
១៤. Sallin, Lena ICRC ក្នុងប្រទេសប៊ូរុនឌី៖ ករណីសិក្សា ខែមិថុនា ឆ្នាំ១៩៩៥។
១៥. Weeks, Willet អង្គការសហព័ន្ធសង្គ្រោះកុមារ (ស.រ.អ) នៅតំបន់ Lower Shabelle (ប្រទេសសូម៉ាលី) ខែកញ្ញា ឆ្នាំ១៩៩៥។

## ដំណាក់កាលផ្តល់យោបល់ត្រលប់ (១៩៩៦-១៩៩៧)

អង្គការ ស៊ីឌីអេ បានរៀបចំករណីសិក្សា ទៅជាសំណុំឯកសារ ទៅតាមប្រភេទនៃបញ្ហា។ ឯកសារបញ្ហាទាំងនេះ បានបង្ហាញនៅក្នុងសិក្ខាសាលាផ្តល់យោបល់ត្រលប់ចំនួន២៣ ដែលកោះប្រជុំតំណាងអង្គការអនុវត្តផ្ទាល់ជាង៧៥០នាក់ មកពីការិយាល័យតាមមូលដ្ឋាន ការិយាល័យកណ្តាល និង ម្ចាស់ជំនួយ។ គោលបំណងសិក្ខាសាលាផ្តល់យោបល់ត្រលប់នេះ គឺដើម្បីប្រៀបធៀបសណ្ឋាន ដែលបានរកឃើញនៅក្នុងករណីសិក្សា នឹងបទពិសោធន៍របស់អ្នកអនុវត្តផ្ទាល់។

*ឯកសារបញ្ហាដែលបានមកពីដំណាក់កាលផ្តល់យោបល់ត្រលប់៖*

១. ជំនួយអន្តរជាតិ និង ទំនាស់៖ ការស្វែងយល់ពីផលជះអវិជ្ជមាន ក្នុងខែកក្កដា ឆ្នាំ១៩៩៧។
២. បទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការបង្ការទំនាស់៖ បញ្ហា និង ទស្សនៈ ខែមេសា ឆ្នាំ១៩៩៥។
៣. អង្គការមនុស្សធម៌ក្នុងការធ្វើអន្តរាគមន៍លើទំនាស់៖ ខែកញ្ញា ឆ្នាំ១៩៩៥។
៤. ទំនាក់ទំនងរវាងជំនួយមនុស្សធម៌ និង ទំនាស់ ព្រមទាំងដំណោះស្រាយដែលអាចធ្វើបាន ខែតុលា ឆ្នាំ១៩៩៥។

ឯកសារបញ្ហានានា ត្រូវបានចាត់ទុកថាជា **"ឯកសារអន្តរកាល"** នៃគម្រោងរៀនសូត្ររួមគ្នា ។ ឯកសារទាំងនេះបង្ហាញនូវសណ្ឋានបឋម ដែលបានកំណត់ក្នុងដំណើរការ និង ធ្វើការកែសម្រួល ព្រមទាំងធ្វើបច្ចុប្បន្នភាព ដោយផ្អែកលើសិក្ខាសាលាផ្តល់យោបល់ត្រលប់ ។ បន្ទាប់ពីដំណាក់កាលផ្តល់យោបល់ត្រលប់ត្រូវបានបញ្ចប់ ឯកសារបញ្ហារបស់ឧបករណ៍មិនបង្កទំនាស់ ត្រូវបានប្រើប្រាស់ដើម្បីធ្វើការបោះពុម្ពផ្សាយចុងក្រោយ។

*ឯកសារបោះពុម្ពផ្សាយ៖*

Anderson, Mary B *ឧបករណ៍មិនបង្កទំនាស់៖ តើជំនួយអាចគាំទ្រដល់សន្តិភាព ឬ សង្គ្រាមយ៉ាងដូចម្តេច* Boulder, CO: អ្នកបោះពុម្ពផ្សាយ Lynne Rienner ឆ្នាំ១៩៩៩។

បញ្ជីសិក្ខាសាលាយោបល់ត្រលប់ និងទីតាំងរបស់សិក្ខាសាលា៖

| ទីតាំងសិក្ខាសាលា | កាលបរិច្ឆេទ | អង្គការឧបត្ថម្ភ | អ្នកបណ្តុះបណ្តាល |
|---|---|---|---|
| ក្រុងម៉ុងរ៉ូវីយ៉ា ប្រទេសលីបេរីយ៉ា | ២៥-២៧ តុលា ១៩៩៦ | អង្គការ CARE International, LCPP | Willet Weeks, Kenny Gluck |

| | | | |
|---|---|---|---|
| ក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា (ប្រទេសស៊ូដង់ខាងត្បូង) | ៦-៩ មករា ១៩៩៧ | អង្គការ USAID | Mary B. Anderson |
| ក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា | ១០-១២ មករា ១៩៩៧ | អង្គការ CRS Sudan | Mary B. Anderson, Wolfgang Heinrich |
| ក្រុងអូតាវ៉ា ប្រទេសកាណាដា | ២១-២២ មករា ១៩៩៧ | អង្គការ CARE Canada, LCPP | Mary B. Anderson, Greg Hansen |
| ប្រទេសដាណាម៉ាក | ២៨-២៩ មករា ១៩៩៧ | អង្គការ DanChurch Aid | Mary B. Anderson |
| ក្រុងសារ៉ាយ៉េវ៉ូ ប្រទេសបូស្នី | ១០-១២ កុម្ភៈ ១៩៩៧ | អង្គការ CRS | Mary B. Anderson, Sam Engelstad, Janis Lindsteadt |
| ក្រុងសាគ្រេប ប្រទេសក្រូអាស៊ី | ១៣-១៥ កុម្ភៈ ១៩៩៧ | អង្គការ CRS | Janis Lindsteadt, SamEngelstad |
| ក្រុងហ្គោឌូរី ប្រទេសហ្សកហ្ស៊ី (តំបន់ Trans Caucasus) | ១៨-២០ កុម្ភៈ ១៩៩៧ | អង្គការ Oxfam GB | Kenny Gluck, Greg Hansen |
| Nazran, ក្រុងណាស់រ៉ាន់ សាធារណៈរដ្ឋ Ingushetia (តំបន់ North Caucasus) | ២៥-២៧ កុម្ភៈ ១៩៩៧ | អង្គការ Merlin, UNHCR | Greg Hansen, Kenny Gluck |
| ក្រុងអាម៉េដដាបាដ ប្រទេសឥណ្ឌា | ១២-១៤ មីនា ១៩៩៧ | អង្គការ St. Xavier's Social Service Society | Greg Hansen, Pia Jertfelt, Joe Bock |
| ក្រុងអូស្លូ ប្រទេសន័រវែស | ១៨-១៩ មីនា ១៩៩៧ | | Mary B. Anderson |
| ប្រទេសកម្ពុជា | ១៩-២១ មីនា ១៩៩៧ | អង្គការ UNDP, CARE | Sam Engelstad, Joergen Kristensen |
| ប្រទេសដាណឺម៉ាក | ២០ មីនា ១៩៩៧ | អង្គការ DanChurch Aid | Mary B. Anderson |
| សហរដ្ឋអាមេរិក | ២ មេសា ១៩៩៧ | អង្គការ Oxfam America (in-house) | Mary B. Anderson |
| ក្រុងគីហ្កាលី ប្រទេសរ្វ៉ាន់ដា | អង់គ្លេស៖ ២៨-៣០ មេសា ១៩៩៧ | អង្គការ World Vision | Mary B. Anderson, Willet Weeks |
| ក្រុងគីហ្កាលី ប្រទេសរ្វ៉ាន់ដា | បារាំង៖ ៥-៧ ឧសភា ១៩៩៧ | អង្គការ World Vision | Mary B. Anderson, Willet Weeks |
| ប្រទេសហ្គាតេម៉ាឡា | ១២ មិថុនា ១៩៩៧ | អង្គការ CRS (in-house) | Kenny Gluck |
| ទីក្រុងប៊ិន ប្រទេសអាល្លឺម៉ង់ | ១២-១៤ មិថុនា ១៩៩៧ | អង្គការ EZE | Mary B. Anderson, Greg Hansen |

| | | | |
|---|---|---|---|
| ប្រទេសស្រីលង្កា | ១៧-១៩ មិថុនា ១៩៩៧ | អង្គការ CARE, NGO Consortium, RRAN | Greg Hansen, Sam Engelstad |
| ប្រទេសហៃទៃ | ៦-១៨ មិថុនា ១៩៩៧ | អង្គការ Canada-Haiti Humanitarian Alliance | Stephen Jackson, Laura Frost, Janis Lindsteadt |
| ប្រទេសហ្គាតេម៉ាឡា | ២៤-២៦ មិថុនា ១៩៩៧ | អង្គការ Radda Barna | Kenny Gluck, Inger Bjork |
| ប្រទេសកូឡុំប៊ី | ១-៣ កក្កដា ១៩៩៧ | អង្គការ Swedish Red Cross | Inger Bjork, Kenny Gluck |
| ប្រទេសអង់ហ្គោឡា | មិថុនា ១៩៩៧ | អង្គការ CRS | Per Midteide, Wolfgang Heinrich |

## ដំណាក់កាលអនុវត្ត (១៩៩៧-២០០១)

នៅក្នុងដំណាក់កាលអនុវត្តឧបករណ៍មិនបង្កទំនាស់ អង្គការ ស៊ីឌីអេ បានបញ្ជូនមន្ត្រីទំនាក់ទំនងទៅកាន់មូលដ្ឋានដើម្បីគាំទ្រដល់អង្គការចំនួន១២ ក្នុងការអនុវត្តមេរៀនដែលទទួលបានពីករណីសិក្សា និងដំណាក់កាលផ្តល់យោបល់ត្រលប់។ គោលបំណងគឺដើម្បីបង្ហាញពីអត្ថប្រយោជន៍របស់ក្របខ័ណ្ឌនៃឧបករណ៍មិនបង្កទំនាស់ និងដើម្បីធ្វើឲ្យប្រសើរឡើង នូវជម្រើសនៃការអនុវត្តកម្មវិធីប្រចាំថ្ងៃរបស់បុគ្គលិកគម្រោងក្នុងបរិបទផ្សេងៗជុំវិញពិភពលោក។ តួនាទីមន្ត្រីទំនាក់ទំនងរួមមាន៖

1. ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់ការអនុវត្តឧបករណ៍មិនបង្កទំនាស់
2. ផ្តល់ប្រឹក្សាអំពីរបៀបប្រើប្រាស់ក្របខ័ណ្ឌការងាររបស់ឧបករណ៍មិនបង្កទំនាស់ និង
3. ធ្វើការប្រមូលលទ្ធផលរបស់អង្គការដែលបានអនុវត្តឧបករណ៍មិនបង្កទំនាស់។

ក្នុងដំណាក់កាលនេះ អង្គការ ស៊ីឌីអេ បានរៀបចំផ្តល់ប្រឹក្សាចំនួន ២ដង ក្នុងមួយឆ្នាំ ដើម្បីជួបជុំមន្ត្រីទំនាក់ទំនង និងអង្គការអនុវត្តផ្ទាល់ ក្នុងគោលបំណងធ្វើការចែករំលែកបទពិសោធន៍ក្នុងការប្រើប្រាស់ក្របខ័ណ្ឌនេះ។ ដំណាក់កាលអនុវត្តនេះ ជាការសាកល្បងមួយ ទៅលើឧបករណ៍ដែលបានបង្កើតឡើងពីករណីសិក្សា និងសិក្ខាសាលាផ្តល់យោបល់ត្រលប់។ ដំណាក់កាលអនុវត្តក៏បានចងក្រងនូវបណ្តុំបទពិសោធន៍ថ្មីៗ សម្រាប់បន្ថែមទៅលើការរៀនសូត្រ និង ធ្វើតេស្តលើការរៀនសូត្រ។ លើសពីនេះ ដំណាក់កាលអនុវត្តបានផ្តល់នូវមធ្យោបាយ ដើម្បីពិនិត្យមើលចំណេះដឹងដែលទទួលបាន និងមេរៀនជាបទពិសោធន៍នៅក្នុងដំណាក់កាលទាំងពីរនាពេលកន្លងមក។

អ្នកអនុវត្តជាច្រើនរយនាក់បន្ថែមទៀត បានចូលរួមក្នុងដំណាក់កាលអនុវត្តនេះ។ ដំណើរការរៀនសូត្រកើតមានពេញមួយវដ្ត ដោយមិនមានការបញ្ចប់នោះទេ។ អ្នកអនុវត្តទាំងអស់ ធ្វើការពិភាក្សាជជែកដេញដោល សាកល្បង និងបានបន្ថែមទៅលើការរៀនសូត្រ។ ដំណាក់កាលនេះ បានធ្វើឲ្យឧបករណ៍មិនបង្កទំនាស់កាន់តែប្រសើរឡើង និងបានបង្កើនការយល់ដឹងពី អ្វីទៅជាទំនាស់/ជម្លោះសម្រាប់ អង្គការមួយ ដើម្បីមានលទ្ធភាពឆ្លើយតបនឹងទំនាស់/ជម្លោះ ។ នៅចុងបញ្ចប់នៃដំណើរការនេះ

ឧបករណ៍មិនបង្កទំនាស់ ពិតជាឧបករណ៍ដ៏មានសក្តានុពល និងជាបណ្តុំនៃទស្សនាទានដែលអាចផ្លាស់ប្តូររបៀបធ្វើការងាររបស់បុគ្គលិក និងស្ថាប័នឲ្យកាន់តែប្រសើរឡើង។

*ការបោះពុម្ពផ្សាយសំខាន់ៗពីដំណាក់កាលអនុវត្ត*

Anderson, Mary B *ជម្រើសសម្រាប់ជំនួយក្នុងទំនាស់ មេរៀនពីបទពិសោធន៍នៅមូលដ្ឋាន* ទីក្រុងខេមប្រ៊ីជ រដ្ឋម៉ាសាឈូសេដ គម្រោងរៀនសូត្ររួមគ្នារបស់អង្គការ ស៊ីឌីអេ ឆ្នាំ២០០០។

## ដំណាក់កាលបញ្ជ្រាប (២០០១-បច្ចុប្បន្ន)

ដំណាក់កាលទីបួននៃឧបករណ៍មិនបង្កទំនាស់ ហៅថា **"ដំណាក់កាលបញ្ជ្រាប"** ពីព្រោះវាជាការខិតខំនាំយកការអនុវត្តឧបករណ៍មិនបង្កទំនាស់ ទៅក្នុងសកម្មភាពផ្តល់ជំនួយ។ ដំណាក់កាលនេះបន្តអនុវត្តរហូតមកដល់សព្វថ្ងៃ ដោយព្យាយាមពង្រីកក្របខ័ណ្ឌការងារឧបករណ៍មិនបង្កទំនាស់ និងការអនុវត្តគម្រោងដោយមាន **ការយកចិត្តទុកដាក់នឹងទំនាស់** (Conflict Sensitivity) ក្នុងចំណោម អ្នកធ្វើការផ្នែកផ្តល់ជំនួយ និង ដើម្បីបន្តការរៀនសូត្រពីបញ្ហាដែលពួកគេជួបប្រទះក្នុងការអនុវត្ត ការធ្វើសមាហរណកម្ម និង ដំណើរការ។

## ការរៀនសូត្រថ្មីៗ៖ ករណីសិក្សាបែបឆ្លុះបញ្ចាំង (ឆ្នាំ២០០៦-២០១២)

ក្នុងឆ្នាំ២០០៦ អង្គការ ស៊ីឌីអេ នៅតែចូលរួមក្នុងការផ្សព្វផ្សាយឧបករណ៍មិនបង្កទំនាស់ ដោយព្យាយាមទាក់ទាញម្ចាស់ជំនួយ តាមរយៈគោលនយោបាយរបស់ពួកគេ ការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអង្គការនានា និង គាំទ្រអ្នកអនុវត្តដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ។ ទោះជាយ៉ាងណាសហការីមួយចំនួនរបស់ ស៊ីឌីអេ យល់ឃើញថា មានអ្វីៗជាច្រើនផ្សេងទៀតដែលត្រូវរៀនសូត្រ ។ អង្គការ ស៊ីឌីអេ ចាប់ផ្តើមសិក្សាថា តើការយកចិត្តទុកដាក់នឹងទំនាស់ (ឬ យុទ្ធសាស្ត្រ និង វិធីសាស្ត្រថ្មីៗ) ត្រូវបានរៀនសូត្រ ប្រើប្រាស់ គិតគូរ ផ្សព្វផ្សាយ និងធ្វើសមាហរណកម្មទៅក្នុងការអនុវត្តដោយគម្រោងរបៀបណា? តាមរយៈអង្គការ ឬ បុគ្គល?

ក្នុងដំណាក់កាលនេះ ករណីសិក្សាចំនួន១៩ ត្រូវបានសរសេរ និង កត់ត្រានូវបញ្ហាប្រឈមរបស់អង្គការផ្សេងៗក្នុង១៧ប្រទេស។ ដោយផ្អែកលើការយល់ដឹងថ្មីៗ អំពីការអនុវត្តនាពេលបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងការសិក្សា និង បន្សុីការអនុវត្តឧបករណ៍មិនបង្កទំនាស់ របស់បុគ្គល គោលនយោបាយ និងស្ថាប័ន។ អង្គការ ស៊ីឌីអេ បានបង្កើតការណែនាំ និង យុទ្ធសាស្ត្របណ្តុះបណ្តាលថ្មីបន្ថែមទៀត។

*ការបោះពុម្ពផ្សាយសំខាន់ៗពីដំណាក់កាលករណីសិក្សាបែបឆ្លុះបញ្ចាំង៖*

១. Goddard, Nicole គោលការណ៍ទូទៅ ដើម្បីអនុវត្តការបណ្តុះបណ្តាលឧបករណ៍មិនបង្កទំនាស់ សម្រាប់ក្រុមគោលដៅផ្សេងៗ ឆ្នាំ២០១៣។

២. Goddard, Nicole និង Maureen Lempke ឧបករណ៍មិនបង្កទំនាស់ នៅក្នុងកម្មវិធីកម្មសិទ្ធិដីធ្លី និងសិទ្ធិលើអចលនទ្រព្យ ទីក្រុង Cambridge រដ្ឋ Massachusetts៖ គម្រោងរៀនសូត្ររួមគ្នារបស់អង្គការ ស៊ីឌីអេ ឆ្នាំ២០១២។

៣. Goddard, Nicole កិច្ចប្រឹងប្រែងបញ្ច្រាបការយកចិត្តទុកដាក់នឹងទំនាស់ ទីក្រុង Cambridge រដ្ឋ Massachusetts គម្រោងរៀនសូត្ររួមគ្នារបស់អង្គការ ស៊ីឌីអេ ឆ្នាំ២០១៤។
៤. Wallace, Marshall ផ្ដើមពីគោលការណ៍ឈានទៅការអនុវត្តៈ មគ្គុទ្ទេសក៍របស់អ្នកប្រើប្រាស់ចំពោះកម្មវិធី Do No Harm ទីក្រុង Cambridge រដ្ឋ Massachusetts គម្រោងរៀនសូត្ររួមគ្នារបស់អង្គការ ស៊ីឌីអេ ឆ្នាំ២០១៤។

## ១.២ តើឧបករណ៍មិនបង្កទំនាស់គឺជាអ្វី?

ឧបករណ៍មិនបង្កទំនាស់ គឺជាឧបករណ៍មួយ សម្រាប់អនុវត្តការយកចិត្តទុកដាក់នឹងទំនាស់ (Conflict Sensitivity) នៅក្នុងគោលនយោបាយ និង កម្មវិធីផ្ដល់ជំនួយ ឬ អនុវត្តគម្រោង។ ការយកចិត្តទុកដាក់នឹងទំនាស់ (Conflict Sensitivity) គឺជាលទ្ធភាពរបស់អង្គការមួយក្នុងការ[1]៖

១. យល់ដឹងពីបរិបទដែលខ្លួនកំពុងធ្វើការ ជាពិសេសសកម្មភាពទំនាក់ទំនងរវាងក្រុម និង ក្រុម និង សកម្មភាពទំនាក់ទំនងក្នុងចំណោមក្រុមនានានៅក្នុងបរិបទនោះ។

២. យល់ដឹងអំពីរបៀប ដែលសេចក្ដីលម្អិត (សកម្មភាព និង ដំណើរការ) នៃការធ្វើអន្តរាគមន៍របស់ខ្លួន មានទំនាក់ទំនងទៅនឹងបរិបទ។ ប្រការនេះ មិនត្រឹមតែគិតគូពីលទ្ធផលនៃការធ្វើអន្តរាគមន៍ប៉ុណ្ណោះទេ ថែមទាំង៖
   ក. សេចក្ដីលម្អិតអំពីកម្មវិធី (ដូចជា៖ ការជ្រើសរើសអ្នកទទួលផល/អ្នកចូលរួម តំបន់ការងារ និង ពេលវេលាអនុវត្តកម្មវិធី ។ល។)
   ខ. សេចក្ដីលម្អិតអំពីប្រតិបត្តិការ (ការជួល លទ្ធកម្ម សន្តិសុខ។ល។)
   គ. ភាពជាក់លាក់ និង ច្បាស់លាស់នៃគោលនយោបាយ (ការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធី និង ប្រតិបត្តិការ)។

៣. ធ្វើសកម្មភាពផ្អែកលើការយល់ដឹងនេះ ដើម្បីកាត់បន្ថយផលជះអវិជ្ជមាន ឲ្យដល់កម្រិតអប្បបរមា នៃការធ្វើអន្តរាគមន៍របស់ខ្លួននៅក្នុងបរិបទ និងបង្កើនផលជះវិជ្ជមានឲ្យដល់កម្រិតអតិបរមា។

ពាក្យថា “ ឧបករណ៍មិនបង្កទំនាស់ ” និងជាភាសាអង់គ្លេស (Do No Harm) ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិស័យផ្ដល់ជំនួយ។ មានការជជែកជាច្រើនអំពីការអនុវត្ត “គោលការណ៍ឧបករណ៍មិនបង្កទំនាស់” ឬការប្រើប្រាស់ “កញ្ចប់ឧបករណ៍មិនបង្កទំនាស់” ។ បុគ្គល និង អង្គការមួយចំនួនបែងចែកឧបករណ៍មិនបង្កទំនាស់ជា២ គឺ **ឧបករណ៍មិនបង្កទំនាស់ចម្បង** (ក្របខ័ណ្ឌឧបករណ៍មិនបង្កទំនាស់) និង **ឧបករណ៍មិនបង្កទំនាស់បន្ទាប់បន្សំ** (គោលការណ៍ ឬ កញ្ចប់ឧបករណ៍មិនបង្កទំនាស់) ។

---

[1] និយមន័យត្រូវបានកែសម្រួលចេញពី International Alert et al “ វិធីសាស្ត្រយកចិត្តទុកដាក់នឹងទំនាស់ចំពោះការអភិវឌ្ឍជំនួយមនុស្សធម៌ និងការកសាងសន្តិភាព៖ កញ្ចប់ធនធាន” ឆ្នាំ២០០៤ ។




គោលការណ៍ឧបករណ៍មិនបង្កទំនាស់ គឺជាអ្វីដែលមានសារៈប្រយោជន៍ និង ភាពវិជ្ជមាន ហើយវាជាមូលដ្ឋាននៃគោលនយោបាយ និង ទស្សនៈវិស័យរបស់អង្គការ ។ ទោះជាយ៉ាងណាមានតែ គោលការណ៍ គឺមិនគ្រប់គ្រាន់ឡើយសម្រាប់ឧបករណ៍មិនបង្កទំនាស់។ ដើម្បីអនុវត្តការយកចិត្តទុកដាក់នឹងទំនាស់ (Conflict Sensitivity) ឧបករណ៍វិភាគ និង វិធីសាស្ត្រអនុវត្តជាតម្រូវការចាំបាច់។ ទាំងអស់នេះ គឺជាក្របខ័ណ្ឌការងារឧបករណ៍មិនបង្កទំនាស់។ ក្របខ័ណ្ឌនេះ ត្រូវបានបង្កើតឡើងផ្អែកលើមេរៀនសំខាន់ៗចំនួន៦ ដែលបានមកពីករណីសិក្សារបស់ឧបករណ៍មិនបង្កទំនាស់ ដើម្បីសម្រួលដល់អង្គការនានា ក្នុងការស្វែងយល់ពីទំនាក់ទំនងដ៏ស្មុគស្មាញរបស់ក្រុមនានា នៅក្នុងបរិបទនៃប្រតិបត្តិការរបស់ខ្លួន ដោយប្រើប្រាស់ **កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់** ជាវិធីសាស្ត្រវិភាគ សម្រាប់ជួយដល់អង្គការនានាឲ្យយល់ដឹងអំពីរបៀបដែលកម្មវិធី និង គោលនយោបាយរបស់ខ្លួន មានទំនាក់ទំនងជាមួយនឹងភាព ជាក់លាក់នៃបរិបទប្រតិបត្តិការរបស់ខ្លួន ហើយផ្តល់ឲ្យអ្នកអនុវត្ត នូវចំណុចចាប់ផ្តើមមួយ សម្រាប់អនុវត្តកម្មវិធីរបស់ពួកគេ ដើម្បីកាត់បន្ថយផលជះអវិជ្ជមានរបស់កម្មវិធីឲ្យដល់កម្រិតអប្បបរមា និងបង្កើនផលជះវិជ្ជមាននៃកម្មវិធីរបស់ខ្លួន។

ជាជាងនិយាយជាទូទៅអំពី **"ទំនាស់-Harm"** យើងចង់ប្រើភាសាជាក់លាក់ថា "ផលជះអវិជ្ជមានលើកត្តាផ្សារភ្ជាប់រវាង ក្រុម ក និង ក្រុម ខ" ឬ "ផលជះវិជ្ជមានលើកត្តាបែកបាក់រវាង ក្រុម គ និង ក្រុម ឃ" ។ ភាពជាក់លាក់នេះ នឹងជួយយើងឲ្យយល់ដឹងពីប្រភេទនៃទំនាស់ ដែលយើងចង់សំដៅ និងអ្នកណាជាអ្នកទទួលរងឥទ្ធិពលពីទំនាស់នេះ។ ព័ត៌មាននេះជួយយើងឲ្យដោះស្រាយឬសគល់នៃផលជះអវិជ្ជមានជាមួយនឹងជម្រើសកម្មវិធី។ វាជួយភ្ជាប់កម្មវិធីរបស់យើងទៅនឹងការវិភាគ និង បង្កើនការយល់ដឹងអំពីបរិបទឲ្យកាន់តែច្បាស់ថែមទៀត។

## ១.៣ ការយកចិត្តទុកដាក់នឹងទំនាស់ និង ការកសាងសន្តិភាព

ការយកចិត្តទុកដាក់នឹងទំនាស់ និង ការកសាងសន្តិភាព ផ្តោតសំខាន់លើទំនាក់ទំនងជាលក្ខណៈអន្តរក្រុម និង ទំនាស់។ ទោះជាយ៉ាងណា ការយកចិត្តទុកដាក់នឹងទំនាស់ មិនមែនជាការកសាងសន្តិភាព ហើយកម្មវិធីកសាងសន្តិភាព ក៏មិនមែនជាការយកចិត្តទុកដាក់នឹងទំនាស់ទាំងអស់នោះទេ ដោយផ្អែកលើការធ្វើការលើទំនាស់របស់ពួកគេ។ ការយកចិត្តទុកដាក់នឹងទំនាស់ គឺជាឧបករណ៍មួយបង្ហាញពីគុណភាព និងប្រសិទ្ធភាពរបស់កម្មវិធី ហើយវាអាចអនុវត្តបានគ្រប់ប្រភេទកម្មវិធីទាំងអស់ ។

ការកសាងសន្តិភាព គឺជាគោលដៅរបស់កម្មវិធី។ ការជម្រុញការអនុវត្តយ៉ាងយកចិត្តទុកដាក់លើការយកចិត្តទុកដាក់នឹងទំនាស់ ដោយផ្តោតលើការកសាងទំនាក់ទំនង និង កាត់បន្ថយភាពប្រេះឆាក្នុងចំណោមក្រុមនានា អាចជួយកសាងសន្តិភាពបាន។ មិនមានការបែងចែកច្បាស់លាស់រវាងប្រធានបទទាំងពីរនេះទេ ផ្ទុយទៅវិញ វាជះស្រមោលលើគ្នាទៅវិញទៅមក ហើយបង្កើតឲ្យមានការភ័ន្តច្រឡំថា តើមានអ្វីជាក់លាក់ដែលត្រូវការចាំបាច់ សម្រាប់ធ្វើអន្តរាគមន៍ក្នុងបរិបទទំនាស់? តើផលជះនៃការធ្វើអន្តរាគមន៍ទាំងនោះមានអ្វីខ្លះ? មេរៀននេះព្យាយាមផ្តល់ភាពច្បាស់លាស់ អំពីប្រភេទផ្សេងៗនៃផលជះដែលចង់បាន និង របៀបកំណត់ ដើម្បីឱ្យគោលដៅនៃការធ្វើអន្តរាគមន៍ទំនាស់ត្រូវបានបំពេញ។

វិធីសាស្ត្រផ្សេងៗគ្នាទាំងនេះ ត្រូវបានចែកចេញជាពីរប្រភេទគឺៈ វិធីសាស្ត្រធ្វើការ “**ក្នុង**” ទំនាស់ និងវិធីសាស្ត្រសម្រាប់ធ្វើការ “**លើ**” ទំនាស់ ។ ការធ្វើការនៅ ក្នុង និង លើ ទំនាស់ តម្រូវឲ្យមានការវិភាគ និង ការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា។ ប្រការសំខាន់ អង្គការនានាត្រូវពិនិត្យមើលគោលដៅ និងទ្រឹស្តីនៃការផ្លាស់ប្តូរ (Theories of Change) របស់ពួកគេ ដើម្បីពិនិត្យឲ្យបានច្បាស់លាស់ អំពីអ្វីដែលពួកគេកំពុងព្យាយាមសម្រេច ដោយកំណត់យកវិធីសាស្ត្រសមស្រប ដើម្បីសម្រួលដល់ការងាររបស់ខ្លួន ទោះជាយ៉ាងណា ត្រូវចងចាំថា នៅពេលកម្មវិធីមួយកំពុងធ្វើការ **លើទំនាស់** វាក៏ត្រូវធ្វើការ **ក្នុងទំនាស់** ផងដែរ។




ការយកចិត្តទុកដាក់នឹងទំនាស់ គឺជាការពិនិត្យមើលពីខាងផ្នែកក្នុង ចេញទៅផ្នែកខាងក្រៅ។ ទាំងនេះគឺជាក្តីបារម្ភជាចម្បងអំពីអ្វីដែលកម្មវិធីកំពុងធ្វើ មានផលជះយ៉ាងដូចម្តេចទៅលើផ្នែកផ្សេងៗនៃបរិបទ។ កម្មវិធីកសាងសន្តិភាព បង្កើតឡើងដើម្បីដោះស្រាយសកម្មភាពទំនាស់យ៉ាងសកម្ម តាមរយៈការកាត់បន្ថយភាពធ្ងន់ធ្ងរនៃទំនាស់ ឬ តាមរយៈការជួយដោះស្រាយបុព្វហេតុ និង កត្តាជម្រុញឲ្យមានទំនាស់។ កម្មវិធីទាំងនេះធ្វើការលើសកម្មភាពទំនាស់ កាត់បន្ថយទំនាស់ បង្ការទំនាស់ និង កសាង

សន្តិភាព។ ពិតណាស់ ការដោះស្រាយសកម្មភាពទំនាស់ តម្រូវឲ្យមានការយកចិត្តទុកដាក់ និងកសាងទំនាក់ទំនងជាមួយក្រុមផ្សេងៗនៅក្នុងបរិបទ។

## ១.៤ មេរៀនចំនួន៦ របស់ឧបករណ៍មិនបង្កទំនាស់

ឧបករណ៍មិនបង្កទំនាស់ ទទួលបានមេរៀនចំនួន៦ អំពីទំនាក់ទំនងរវាងជំនួយ និង ទំនាស់ ដែលមាននៅក្នុងក្របខ័ណ្ឌការងារទំនាក់ទំនងរបស់ឧបករណ៍មិនបង្កទំនាស់។ យើងហៅ ក្របខ័ណ្ឌការងារនេះថា ជាក្របខ័ណ្ឌការងារទំនាក់ទំនង ពីព្រោះវាបង្ហាញពីទំនាក់ទំនងរវាងធាតុផ្សំនានា នៅក្នុងបរិបទមួយ និង របៀបដែលធាតុផ្សំទាំងនេះមានទំនាក់ទំនងគ្នា បង្កើតបានជា ផលជះអវិជ្ជមាន ឬ ផលជះវិជ្ជមាន ទៅលើបរិបទនៃទំនាស់។

### មេរៀនទី១៖ នៅពេលដែលអន្តរាគមន៍ណាមួយចូលទៅក្នុងបរិបទមួយ វាក្លាយជាផ្នែកមួយនៃបរិបទនោះ

ប្រការនេះ មិនងាយស្រួលយល់សម្រាប់អ្នកខាងក្រៅនោះទេ ពួកគេមានអារម្មណ៍ថា ពួកគេ ឬ សកម្មភាពពួកគេ មិនមានឥទ្ធិពលលើបញ្ហា ឬ ទំនាស់នៅក្នុងបរិបទនោះទេ។ ការក្លាយជាផ្នែកមួយនៃបរិបទ គឺជារឿងមួយដែលមិនអាចជៀសផុតបាន។ នៅពេលដែលអន្តរាគមន៍មួយ ចូលទៅក្នុងបរិបទ វានឹងចាប់ផ្តើមមានផលជះ ដែលអាចកើតមានលើសពីអ្វីដែលយើងចង់បានទៅទៀត។ ឧបករណ៍មិនបង្កទំនាស់ ដោះស្រាយ/ការពាររាល់ផលជះដែលយើងមិនចង់បានទាំងនេះ។

### មេរៀនទី២៖ រាល់បរិបទទាំងអស់ត្រូវបានកំណត់ដោយកត្តាចំនួនពីរគឺ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

**កត្តាបែកបាក់** គឺជាកត្តាទាំងឡាយណាដែលបង្កើតឲ្យមានការបែកបាក់ ឬ ភាពតានតឹងក្នុងចំណោមបុគ្គល ឬ ក្រុមនានា។ កត្តាទាំងនេះជម្រុញឲ្យមនុស្សឃ្លាតឆ្ងាយពីគ្នា។

**កត្តាផ្សារភ្ជាប់** គឺជាកត្តាទាំងឡាយណាដែលនាំយកបុគ្គល និង ក្រុមមនុស្ស មករួមគ្នា។

កត្តាទាំងពីរនេះ ត្រូវបានរកឃើញនៅក្នុងគ្រប់បរិបទទាំងអស់។ សូម្បីនៅក្នុងបរិបទសន្តិភាពបំផុត យើងនៅតែឃើញមានកត្តាបែកបាក់ ហើយនៅក្នុងពេលកើតមានទំនាស់ ប្រកបដោយអំពើហិង្សាបំផុត ក៏យើងនៅឃើញមានកត្តាផ្សារភ្ជាប់។

### មេរៀនទី៣៖ អន្តរាគមន៍មួយ មានទំនាក់ទំនងទាំងជាមួយកត្តាបែកបាក់ ទាំងកត្តាផ្សារភ្ជាប់

ការធ្វើអន្តរាគមន៍មួយ អាចមានផលជះអវិជ្ជមាន ដោយបង្កើនភាពតានតឹងរបស់មនុស្ស ឬ កាត់បន្ថយកត្តាផ្សារភ្ជាប់ និង ធ្វើឲ្យកត្តាផ្សារភ្ជាប់ចុះខ្សោយ ឬ វាអាចមានផលជះវិជ្ជមាន តាមរយៈការកាត់បន្ថយការបែកបាក់ឲ្យដល់កម្រិតអប្បបរមា និង បង្កើនទំនាក់ទំនងរបស់មនុស្សក្នុងសហគមន៍។ គ្រប់អង្គការដែលធ្វើអន្តរាគមន៍នៅក្នុងបរិបទស្មុគស្មាញ រំពឹងថានឹងទទួលបានផលជះវិជ្ជមាន។ ឧបករណ៍មិនបង្កទំនាស់ ជួយយើងឲ្យដឹងនូវផលជះដែលយើងមិនចង់បាន ទៅលើកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ដែលអាចរារាំងដល់គោលដៅវិជ្ជមាន ដែលបានកំណត់។

## មេរៀនទី៤៖ សណ្ឋានផលជះអាចព្យាករណ៍ទុកបានតាមរយៈអន្តរអំពើរវាងជំនួយនឹងទំនាស់

សណ្ឋានទូទៅនៃផលជះ តាមរយៈអង្គការ និង បុគ្គល ដែលបង្កើតផលជះលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ តាមរយៈ សកម្មភាព **(ការផ្ទេរធនធាន)** និង ឥរិយាបថបុគ្គលិក **(សារបង្កប់ក្រមសីលធម៌)**។ អង្គការដាក់ចូលប្រភេទធនធានផ្សេងៗទៅក្នុងបរិបទមួយ។ តើធនធានអ្វីត្រូវបាននាំយកទៅក្នុងបរិបទ? ត្រូវនាំយកទៅតាមរបៀបណា? អ្វីដែលយើងធ្វើ វាបង្ហាញឲ្យឃើញច្រើនជាងអ្វីដែលយើងនិយាយ តើសារអ្វីដែលយើងបញ្ជូនតាមរយៈឥរិយាបថរបស់យើង? ភ័ស្តុតាងពីឧបករណ៍មិនបង្កទំនាស់បានបង្ហាញឲ្យឃើញថា មានសណ្ឋានជាក់លាក់មួយចំនួន ដែលមានផលជះលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។

## មេរៀនទី៥៖ សេចក្តីលម្អិតនៃអន្តរាគមន៍របស់គម្រោង គឺជាបញ្ហា

អន្តរាគមន៍ទាំងមូល គឺជាបណ្តុំនៃជម្រើស។ ជារួម (គោលដៅ) អន្តរាគមន៍កម្រជាប្រភពនៃផលជះអវិជ្ជមានលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ណាស់។ ផ្ទុយទៅវិញ សេចក្តីលម្អិត (ដែលគិតថាមិនសូវសំខាន់) គឺជាប្រភពដែលនាំឲ្យសណ្ឋានផលជះកើតមានឡើង។ យើងបានសង្កេតឃើញថា ប្រសិនបើអន្តរាគមន៍មួយបង្កឲ្យមានផលជះអវិជ្ជមាន ដែលយើងមិនចង់បាន នោះវាមិនចាំបាច់ត្រូវផ្លាស់ប្តូរ គោលដៅ ឬ សកម្មភាពភាគច្រើននោះទេ។ ផ្ទុយទៅវិញ គេអាចកែសម្រួលសេចក្តីលម្អិតមួយចំនួន ដែលចាំបាច់សម្រាប់សកម្មភាពទាំងនោះ។ គោលដៅដូចគ្នា អាចសម្រេចបានតាមមធ្យោបាយផ្សេងៗគ្នា។

## មេរៀនទី៦៖ ជម្រើសតែងតែមាន

យើងតែងតែអាចធ្វើអ្វីមួយ តាមរបៀបផ្សេងៗគ្នា ខុសពីអ្វីដែលយើងកំពុងធ្វើ។ ជានិច្ចកាល យើងអាចរៀនសូត្រ និង កែលម្អខ្លួនឯង ប្រសិនបើយើងមើលឃើញថា យើងកំពុងមានផលជះអវិជ្ជមាននោះ យើងអាចធ្វើការកែសម្រួលបាន។ ហើយបើយើង មានផលជះវិជ្ជមាន នោះយើងអាចរក្សាឱ្យគង់វង្ស ឬ ពង្រីកបន្ថែម។

ទាំងនេះ គឺជាមេរៀនជាមូលដ្ឋានរបស់ឧបករណ៍មិនបង្កទំនាស់ និង ជាក្របខ័ណ្ឌ ដែលបានបង្កើតឡើង។ ក្របខ័ណ្ឌការងារនេះ អាចជួយយើងឲ្យវិភាគការងារផ្ទាល់របស់យើង និងជួយឲ្យយើងយល់ដឹងអំពីទំនាក់ទំនង រវាងអ្វីដែលយើងកំពុងធ្វើ និង បរិបទដែលយើងកំពុងប្រតិបត្តិការ។

ក្របខ័ណ្ឌការងារឧបករណ៍មិនបង្កទំនាស់ អាចគូរនៅលើផ្ទាំងក្រដាស (ឬបង្កើតជាស្លាយ) នៅពេលអ្នកធ្វើបទបង្ហាញអំពីមេរៀនទាំង៦។ វាអាចបិទលើជញ្ជាំងក្នុងអំឡុងពេលសិក្ខាសាលា ឬ ចែកជូនសិក្ខាកាមធ្វើជាឯកសារ។

## ក្របខ័ណ្ឌឧបករណ៍មិនបង្កទំនាស់ សម្រាប់ការវិភាគពីផលជះរបស់ជំនួយលើទំនាស់



## ២. ៧ ជំហាននៃដំណើរការឧបករណ៍មិនបង្កទំនាស់

ដើម្បីបង្កើតបានក្របខណ្ឌការងារឧបករណ៍មិនបង្កទំនាស់ (Do No Harm Framework) មួយបាន វាត្រូវឆ្លងកាត់ជំហានទាំង៧ នៃដំណើរការឧបករណ៍មិនបង្កទំនាស់៖

១. ស្វែងយល់ពីបរិបទនៃទំនាស់
២. វិភាគកត្តាបែកបាក់ និងប្រភពនៃភាពតានតឹងក្នុងបរិបទ
៣. វិភាគកត្តាផ្សារភ្ជាប់ក្នុងបរិបទ
៤. ដឹងពីព័ត៌មានលម្អិតសំខាន់ៗនៃអន្តរាគមន៍របស់កម្មវិធី
៥. វិភាគផលជះរបស់អន្តរាគមន៍លើកត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់ តាមរយៈសកម្មភាព និងឥរិយាបថបុគ្គលិក
៦. បង្កើតជម្រើសរៀបចំកម្មវិធី
៧. ធ្វើការសាកល្បងជម្រើស និងរៀបចំអន្តរាគមន៍ឡើងវិញ។

### ដំណើរការកម្មវិធី Do No Harm



# ជំហានទី១៖ ការវិភាគបរិបទ

## គោលបំណង

មេរៀននេះ ណែនាំសិក្ខាកាមអំពីកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ដែលជាឧបករណ៍ដើម្បីស្វែងយល់ពីលក្ខណៈពិសេសនៃបរិបទ។ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ គឺជាឧបករណ៍វិភាគបរិបទចម្បងសម្រាប់ការអនុវត្តឧបករណ៍មិនបង្កទំនាស់។

## ខ្លឹមសារមេរៀន៖ ការវិភាគបរិបទ

ជំហានដំបូងក្នុងដំណើរការឧបករណ៍មិនបង្កទំនាស់ គឺការយល់ដឹងអំពីបរិបទ ដែលអង្គការរបស់អ្នកកំពុងប្រតិបត្តិការ។ មានឧបករណ៍ល្អៗជាច្រើនសម្រាប់វិភាគបរិបទ ហើយ ស៊ីឌីអេ មិនណែនាំនូវឧបករណ៍ណាលើឧបករណ៍ណាឡើយ។ មុននឹងចាប់ផ្តើមវិភាគ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ អ្នកគួរស្វែងយល់អំពីព័ត៌មានគ្រឹះមួយចំនួនអំពីបរិបទដែលអ្នកធ្វើការ។

មានកិច្ចការសំខាន់ៗ ៣ ក្នុងការស្វែងយល់ពីបរិបទ៖

១. កំណត់ធាតុផ្សំនៃតំបន់អនុវត្តកម្មវិធីសម្រាប់ការវិភាគបរិបទ៖

- ក. តើផ្នែកណា (ភូមិសាស្ត្រ ឬ ទស្សនៈ) ដែលពាក់ព័ន្ធនឹងការងារអង្គការរបស់អ្នក?
- ខ. តើកម្មវិធី/អង្គការរបស់អ្នកធ្វើអន្តរាគមន៍នៅកម្រិតណា?
  (ឧទាហរណ៍៖ កម្រិតមូលដ្ឋាន កម្រិតជាតិ...)

២. កំណត់តួអង្គក្នុងបរិបទ៖

- ក. តើមានក្រុម (ជនជាតិ នយោបាយ សង្គម...) ណាខ្លះ នៅក្នុងតំបន់អនុវត្តកម្មវិធី?
- ខ. តើតំបន់អនុវត្តកម្មវិធី ត្រូវបានកំណត់ថាជា "កម្មសិទ្ធិ" ឬ "ទឹកដី" របស់ក្រុមណាមួយដែរឬទេ?
- គ. តើមានអន្តរាគមន៍អ្វីខ្លះ ដែលកំពុងអនុវត្តដែលនឹងមានផលជះលើបរិបទ?
  - i. តើរដ្ឋាភិបាលកំពុងធ្វើអ្វី?
  - ii. តើអង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើអ្វី?
  - iii. តើមានកិច្ចប្រឹងប្រែងរបស់ប្រជាពលរដ្ឋមូលដ្ឋានអ្វីខ្លះបានកើតឡើង?

៣. កំណត់ទំនាស់រវាងក្រុមនិងក្រុម ដែលបង្កហិង្សា ឬ មានគ្រោះថ្នាក់ និង អាចក្លាយទៅជាអំពើហិង្សា។

- ក. តើធ្លាប់មានទំនាស់ណាមួយរវាងក្រុមខាងលើ ដែលក្លាយជាអំពើហិង្សាដែរឬទេ?
- ខ. តើធ្លាប់មានទំនាស់មិនមែនជាអំពើហិង្សា តែគួរឱ្យកត់សម្គាល់ ឬ អាចក្លាយជាអំពើហិង្សាដែរឬទេ?

មិនមែនគ្រប់ទំនាស់ទាំងអស់ សុទ្ធតែជាអំពើហិង្សា មានគ្រោះថ្នាក់ ឬ មានភាពអន្តរាយឡើយ។ ទំនាស់ គឺជាផ្នែកដ៏ធំមួយនៅក្នុងសង្គម។ ការមិនឯកភាពគ្នារវាងបុគ្គល និង បុគ្គល រវាងក្រុម និង ក្រុម អាចក្លាយជាការពិភាក្សាវែកញែកយ៉ាងក្តៅគគុក។ អ្វីដែលជាក្តីកង្វល់ពាក់ព័ន្ធនឹងសិក្ខាសាលានេះ គឺទំនាស់ដែលនាំទៅរកភាពអន្តរាយ អាចមានន័យថាជាអំពើហិង្សា សង្គ្រាម ឬ ទំនាស់ ដែលរារាំងដល់ដំណើរការអភិវឌ្ឍក្នុងសង្គមមួយ។

## ជំហានទី២ និង ទី៣៖ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

ភស្តុតាងបានមកពីឧបករណ៍មិនបង្កទំនាស់បង្ហាញថា គ្រប់បរិបទនៃទំនាស់ កំណត់លក្ខណៈដោយកត្តាពីរយ៉ាងគឺ៖ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់។ អន្តរាគមន៍របស់យើង មានផលជះលើកត្តាទាំង២។ ការវិភាគកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ បំពេញបន្ថែមលើការវិភាគបរិបទរបស់អ្នក។ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ប្រាប់យើងអំពីអ្វីម្យ៉ាងនៅក្នុងបរិបទគឺ៖ **ទំនាក់ទំនងរវាងក្រុមមនុស្ស**។

**កត្តាបែកបាក់** គឺជាអ្វីដែល៖

- បង្កើនភាពតានតឹង ការទាស់ទែងគ្នា ឬ សមត្ថភាពបង្កឲ្យមានសង្គ្រាមរវាងក្រុមមនុស្ស។
- បង្កើនភាពសង្ស័យ ការមិនទុកចិត្ត ឬ វិសមភាពក្នុងសង្គម។

ក្នុងបរិបទទំនាស់ជាក់ស្តែង កត្តាបែកបាក់ ងាយនឹងមើលឃើញ អ្នកអាចឃើញកត្តាទាំងនេះនៅកន្លែងអនុវត្តកម្មវិធី ហើយមានការជជែកគ្នាយ៉ាងផុសផុលអំពីកត្តាទាំងនេះ។ ក្នុងបរិបទទំនាស់បង្កប់ (ទំនាស់ដែលពិបាកមើលឃើញ) កត្តាបែកបាក់ អាចនាំឱ្យមានអំពើហិង្សា ប៉ុន្តែមិនងាយមើលឃើញដោយអ្នកខាងក្រៅបានឡើយ។



**កត្តាផ្សារភ្ជាប់** គឺជាអ្វីដែល៖

- នាំមនុស្សឲ្យមកនៅជាមួយគ្នា ទោះបីជាពួកគេមានភាពខុសគ្នាក៏ដោយ។
- កាត់បន្ថយភាពសង្ស័យ ការមិនទុកចិត្ត និង វិសមភាពក្នុងសង្គម។

ក្នុងបរិបទទំនាស់ ពេលខ្លះកត្តាផ្សារភ្ជាប់មានការលំបាកក្នុងការកំណត់ ឬ រកឲ្យឃើញ។ ហើយក៏មិនសូវមានការជជែកពិភាក្សាអំពីកត្តាទាំងនេះឡើយ ហើយអ្នកខាងក្រៅអាចគិតថាមិនមានកត្តាផ្សារភ្ជាប់ឡើយ។ ប៉ុន្តែយើងឃើញមានកត្តានេះនៅគ្រប់បរិបទទាំងអស់។ ជាការពិត កត្តាផ្សារភ្ជាប់ តែងតែមិនខ្លាំងគ្រប់គ្រាន់ លើកត្តាបែកបាក់ ប៉ុន្តែមិនមានន័យថា វាមិនសំខាន់នោះឡើយ។



## ប្រភេទនៃការវិភាគ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

ការកំណត់កត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់មានភាពងាយស្រួល ប្រសិនបើធ្វើការងារនេះជាក្រុម ហើយកាន់តែងាយទៀត បើក្នុងក្រុមការងារមានប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ប្រភេទនៃការវិភាគខាងក្រោមអាចមានប្រយោជន៍សម្រាប់ការស្វែងរក កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់។

### ប្រព័ន្ធ និង ស្ថាប័ន

សង្គមមួយដំណើរការបានតាមរយៈប្រព័ន្ធ និង ចាត់ចែងការគ្រប់គ្រងតាមរយៈស្ថាប័ន។ រចនាសម្ព័ន្ធទាំងនេះ អាចប្រើប្រាស់ជាកំលាំងប្រកបដោយថាមពល ដែលអាចជួយផ្សារភ្ជាប់ក្រុមមនុស្ស ឬ ជម្រុញឲ្យមានភាពខុសគ្នាធ្វើឱ្យពួកគេបែកបាក់គ្នា។ ប្រព័ន្ធ និង ស្ថាប័ន អាចមានលក្ខណៈបរិយាបន្ន ឬ ផ្ដាច់មុខ ហើយអាចស្របច្បាប់សម្រាប់ទាំងអស់គ្នា ឬ សម្រាប់តែក្រុមមនុស្សខ្លះ។ នៅពេលវិភាគប្រព័ន្ធ និង ស្ថាប័ន យើងចាំបាច់ត្រូវវិភាគលើចំណុចផ្សេងៗទៀតលើសពីយន្តការគ្រប់គ្រងផ្លូវការ ដូចជា ប្រព័ន្ធ និង ស្ថាប័នមិនផ្លូវការ (បែបសាសនា និង បែបប្រពៃណី) ប្រព័ន្ធបច្ចេកវិទ្យា (ទំនាក់ទំនង ប្រព័ន្ធអគ្គិសនី ។ល។) មានសំណួរមួយចំនួនសម្រាប់ការវិភាគនេះ៖

- តើគោលនយោបាយផ្លូវការ ឬ មិនផ្លូវការ ស្ថាប័ន ឬ ប្រព័ន្ធក្នុងស្រុក សេដ្ឋកិច្ច ឬ វប្បធម៌ ណាខ្លះ ធ្វើឱ្យមនុស្សឃ្លាតឆ្ងាយពីគ្នា ឬ បង្កើនភាពតានតឹង រវាងក្រុមមនុស្ស?
- តើស្ថាប័ន ឬ ប្រព័ន្ធ ណាជួយមនុស្សឱ្យជម្នះលើភាពខុសគ្នា ឬ ជម្រុញឲ្យមានការរួមរស់ជាមួយ គ្នា?




### ឥរិយាបថ និង សកម្មភាព

ប្រភេទនេះ សំដៅទៅលើអ្វីដែលមនុស្សនិយាយ និង អ្វីដែលមនុស្សធ្វើ។ មនុស្សអាចជម្រុញកត្តាផ្សារភ្ជាប់ ឬ កត្តាបែកបាក់ តាមរយៈ**សកម្មភាព**របស់ពួកគេ (ឧទាហរណ៍៖ អាកប្បកិរិយាស្វាគមន៍ ឬ អាកប្បកិរិយារំលោភបំពាន) ឬ **ឥរិយាបថ**របស់ពួកគេ (ឧទាហរណ៍៖ ការចែករំលែកសារសន្តិភាព ឬ ការលើកកម្ពស់ក្រុមណាមួយ) ។ ឥរិយាបថ និង សកម្មភាពទាំងនេះ អាចមានទំហំតូច (ការប្រាស្រ័យទាក់ទងគ្នារវាងក្រុមប្រជាពលរដ្ឋក្នុងសហគមន៍) ឬទំហំធំ (អ្វីដែលអ្នកនយោបាយថ្នាក់ជាតិនិយាយ) ។

- តើឥរិយាបថ ផ្ទត់គំនិត ការគម្រាមកំហែង ឬ សកម្មភាពហិង្សាអ្វីដែលកើតមានក្នុងបរិបទ?
- តើក្រុមមនុស្សបង្ហាញភាពអធ្យាស្រ័យ ការទទួលយក ឬការពេញចិត្តទៅក្រុមផ្សេងទៀតដោយរបៀបណា?




## គុណតម្លៃ និង ផលប្រយោជន៍

គុណតម្លៃ និង ផលប្រយោជន៍ គឺជាអ្វីដែលមានសារៈសំខាន់សម្រាប់មនុស្សរួមមាន៖ ក្តីកង្វល់ គោលការណ៍ និង ស្តង់ដាររបស់ពួកគេ។ គុណតម្លៃ និង ផលប្រយោជន៍រួម ផ្សាភ្ជាប់មនុស្ស តែគុណតម្លៃខុសៗគ្នា ឬ ការប្រកួតប្រជែងផលប្រយោជន៍ ធ្វើឲ្យពួកគេបែកបាក់គ្នា។

**ផលប្រយោជន៍** អាចជាសេដ្ឋកិច្ច ឬ នយោបាយ

**គុណតម្លៃ** ជាសីលធម៌ ឬ វប្បធម៌




គុណតម្លៃ និង ផលប្រយោជន៍ បង្ហាញអំពីជំនឿ និង គោលជំហរដែលចាក់ជ្រៅ ឬ រឹងមាំមិនគួរឱ្យជឿ និងពិបាកក្នុងការផ្លាស់ប្តូរ។ គុណតម្លៃ និង ផលប្រយោជន៍ មានសារៈសំខាន់ នៅពេលធ្វើការពិចារណាលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ពីព្រោះវាជួយកំណត់លក្ខណៈអាកប្បកិរិយា និង ការប្រាស្រ័យទាក់ទងរបស់មនុស្ស។ គុណតម្លៃ និង ផលប្រយោជន៍ អាចបង្ហាញនូវហេតុផលនៅពីក្រោយឥរិយាបថ និង សកម្មភាពរបស់គេ។

- តើមានគុណតម្លៃជាក់លាក់អ្វីខ្លះ ដែលមានភាពខុសគ្នាពីក្រុមមួយទៅក្រុមមួយ និង បង្កើតភាពតានតឹង? តើមានគុណតម្លៃជាក់លាក់អ្វីខ្លះ ដែលក្រុមនីមួយៗមានដូចគ្នា?
- តើក្រុមទាំងនេះចែករំលែកផលប្រយោជន៍គ្នាដែរឬទេ? តើពួកគេធ្វើការងារជាមួយគ្នាដែរឬទេ? តើពួកគេមានផលប្រយោជន៍ខុសៗគ្នាពាក់ព័ន្ធនឹងធនធានរួមដែរឬទេ?

## បទពិសោធន៍

**បទពិសោធន៍** គឺជាកត្តារឹងមាំមួយរបស់ កត្តាផ្សាភ្ជាប់ ឬ កត្តាបែកបាក់ ។ បទពិសោធន៍រួម ឬ ដូចគ្នាអាចបង្រួបបង្រួមក្រុមមនុស្សខុសៗគ្នាបាន។ បទពិសោធន៍ខុសៗគ្នានៃហេតុការណ៍មួយ អាចបង្កើតការយល់ឃើញខុសៗគ្នា និង ការបែកបាក់ក្នុងសង្គម។ បទពិសោធន៍ជាក្រុម គឺជាប្រភពនៃរឿងនិទាន និង ប្រវត្តិសាស្ត្រ ហើយហេតុការណ៍ជាប្រវត្តិសាស្ត្រទាំងនេះ នៅតែអាចជាប្រភពនៃការផ្សាភ្ជាប់ ឬ ការបែកបាក់ក្រុមមនុស្សជំនាន់ក្រោយ។ របៀបដែលក្រុមធ្វើការប្រាស្រ័យទាក់ទងគ្នា មានភាពដូចគ្នា ឬ មានភាពខុសគ្នាកាលពីអតីតកាល គឺជាមូលដ្ឋានគ្រឹះនៃទំនាក់ទំនងបច្ចុប្បន្នរបស់ពួកគេ។

- តើក្រុមមនុស្សមានបទពិសោធន៍ពីហេតុការណ៍អតីតកាល ឬ ជាប្រវត្តិសាស្ត្រខុសៗ គ្នាដែរឬទេ?
- តើមានបទពិសោធន៍អ្វី ដែលក្រុមមនុស្សមានរួមគ្នាក្នុងពេលកន្លងមក?





## និមិត្តរូប និង ព្រឹត្តិការណ៍

**និមិត្តរូប** គឺជាតំណាងនៃអ្វីមួយដែលធំជាង ដូចជា៖ ទង់ជាតិតំណាងឱ្យប្រទេសមួយ ឬ ចលនាមួយ ពណ៌តំណាងឱ្យក្រុមមួយ ការដាក់ឈ្មោះផ្លូវដោយប្រើឈ្មោះវីរបុរស តំណាងឱ្យហេតុការណ៍ប្រវត្តិសាស្ត្រណាមួយ។ **ព្រឹត្តិការណ៍** ប្រមូលផ្តុំមនុស្សដើម្បីអបអរ កាន់ទុក្ខ ចងចាំ ឬ ប្រកួតប្រជែងគ្នា។ និមិត្តរូប និង ព្រឹត្តិការណ៍ទាំងនេះ អាចបង្រួបបង្រួមក្រុមមនុស្ស ឬ បំបែកបំបាក់ពួកគេ។ ការប្រើឈ្មោះវីរបុរសដាក់ឈ្មោះផ្លូវ មានការយល់ឃើញខុសៗគ្នា អាស្រ័យលើការចាញ់ ឬ ឈ្នះរបស់ពួកគេនៅក្នុងសង្គ្រាម។ ការប្រារព្ធពិធីអបអរខួបអនុស្សាវរីយ៍ ឬ ឯករាជ្យ អាចប្រមូលផ្តុំក្រុមមនុស្សទាំងអស់។ ការវិភាគនិមិត្តរូប និង ព្រឹត្តិការណ៍ មិនត្រឹមតែថាវាជាអ្វីប៉ុណ្ណោះទេ ថែមទាំងត្រូវវិភាគថា តើវាតំណាងឲ្យអ្វី ឬ មានន័យអ្វីសម្រាប់ក្រុម/ប្រជាពលរដ្ឋ ហើយនរណាដែលវារាប់បញ្ចូល ឬ មិនរាប់បញ្ចូល។

- តើមាននិមិត្តរូប ហេតុការណ៍ ថ្ងៃឈប់សម្រាក ឬ ព្រឹត្តិការណ៍ ដែលអបអរតែក្រុមមួយ ដោយមិនបានរាប់បញ្ចូលក្រុមផ្សេងទៀតដែរឬទេ? តើមានក្រុមណាខ្លះដែលមិនបានរាប់បញ្ចូល?
- តើមាននិមិត្តរូបសកលនៃការរួបរួមគ្នា ឬ សន្តិភាព ដែលមានការទទួលស្គាល់ និង ត្រូវបានអបអរពីក្រុមមនុស្សទាំងអស់ដែរឬទេ?





អ្នកអនុវត្តឧបករណ៍មិនបង្កទំនាស់ ប្រើប្រាស់ប្រភេទទាំងអស់ ដើម្បីជួយពួកគេក្នុងការរិះរកគំនិត និង កំណត់កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ក្នុងបរិបទរបស់ពួកគេ។ មានការយល់ឃើញថា ប្រភេទខាងលើមានអត្ថប្រយោជន៍ខ្លាំង ប៉ុន្តែមិនមានន័យថា វាជាវិធីសាស្ត្រតែមួយគត់ក្នុងការកំណត់ប្រភេទនៃកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ នោះទេ។ អ្នកអាចស្វែងរកដំណើរការ កំណត់កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ដែលសមស្របសម្រាប់អ្នក និង ក្រុមការងាររបស់អ្នក។

## ការពិចារណាក្នុងការវិភាគបរិបទ

មានការពិចារណាសំខាន់ៗមួយចំនួន នៅពេលធ្វើការកំណត់ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់៖

## ការកំណត់អាទិភាព កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់

នៅពេលធ្វើបញ្ជី កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ យើងអាចរកឃើញកត្តាជាច្រើន ក្នុងបរិបទដែលបង្កើនភាពតានតឹង ឬ ប្រមូលផ្តុំក្រុមមនុស្ស។ វាមានភាពលំបាកខ្លាំងក្នុងការដាក់បញ្ចូល កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ច្រើនក្នុងការរៀបចំកម្មវិធី ឬ ធ្វើការតាមដានគ្រប់ពេលវេលា។ អ្នកអនុវត្តឧបករណ៍មិនបង្កទំនាស់ ធ្វើការកំណត់អាទិភាព កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ដើម្បីត្រួតពិនិត្យការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពចំពោះកត្តាទាំងនេះ។ មានការកំណត់អាទិភាព កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់តាមរយៈមធ្យោបាយផ្សេងៗគ្នា ប៉ុន្តែជាធម្មតា យើងអាចសួរសំណួរថា៖

- តើកត្តាបែកបាក់ណាខ្លះដែលមានគ្រោះថ្នាក់ ឬ បង្កនូវភាពតានតឹងខ្លាំងបំផុតរវាងក្រុមមនុស្ស?
- តើកត្តាផ្សាភ្ជាប់ណាខ្លះ អាចធ្វើការងារជាមួយ និង មានផលជះជាវិជ្ជមាន?

## មនុស្សជា កត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់

មានការប៉ុនប៉ងក្នុងការកំណត់បុគ្គលជា កត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់ ក្នុងបរិបទ។ តែគឺ **សកម្មភាព និង អាកប្បកិរិយា**ជាក់លាក់របស់ពួកគេ ដែលមានផលជះបែកបាក់ ឬ ផ្សាភ្ជាប់ មិនមែនបុគ្គលនោះផ្ទាល់ទេ។ មនុស្សអាចជា **និមិត្តរូប** សម្រាប់ចលនា ប្រព័ន្ធ ឬ ស្ថាប័នមួយ។

នៅពេលយកមនុស្ស ជាពិសេសអ្នកនៅមានជីវិតជា និមិត្តរូបនៃកត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់ សូមពិនិត្យមើលការវិភាគរបស់អ្នកឱ្យបានទៀងទាត់។ មនុស្សម្នាក់អាចផ្លាស់ប្តូរ អាកប្បកិរិយា និង សកម្មភាពរបស់ខ្លួនយ៉ាងឆាប់រហ័ស ហើយបុគ្គលម្នាក់ដែលជានិមិត្តរូប សម្រាប់ចលនាសន្តិភាព អាចក្លាយជាតួអង្គមួយក្នុងប្រព័ន្ធដែលគាំទ្រអំពើហិង្សា។ ជាពិសេសសម្រាប់អ្នកដែលជានិមិត្តរូបរបស់កត្តាផ្សាភ្ជាប់ នៅក្រៅរចនាសម្ព័ន្ធគ្រប់គ្រង (ឧទាហរណ៍៖ លោក ណែលសាន់ ម៉ាន់ដេឡា និង លោកស្រី អ៊ុងសានស៊ូជី) ខណៈពេលតួអង្គទាំងនេះនៅក្រៅប្រព័ន្ធ ពួកគេជានិមិត្តរូបនៃចលនាមួយ។ នៅពេលពួកគេក្លាយជាផ្នែកនៃរដ្ឋាភិបាល (អាហ្វ្រិកខាងត្បូង មីយ៉ាន់ម៉ា) ពួកគេត្រូវធ្វើការសម្រេចចិត្តផ្នែកនយោបាយ ដែលអាចផ្លាស់ប្តូរជំហររបស់ពួកគេ ធ្វើឱ្យឥទ្ធិពលផ្សាភ្ជាប់របស់ពួកគេថយចុះ។

## នៅពេលអ្វីមួយហាក់ដូចជា កត្តាបែកបាក់ផង និង កត្តាផ្សាភ្ជាប់ផង

នៅពេលធ្វើការវិភាគ ពេលខ្លះកត្តាមួយ អាចបំបែកបំបាក់ក្រុមមនុស្សផង និង អាចផ្សាភ្ជាប់ពួកគេផង។ ក្នុងករណីនេះ អ្នកចាំបាច់ត្រូវធ្វើការបំបែកសំណួរដោយសួរខ្លួនឯងថា៖

- តើកត្តានេះកំពុងបំបែកបំបាក់ក្រុមមនុស្សដោយរបៀបណា?
- តើកត្តានេះកំពុងផ្សាភ្ជាប់ក្រុមមនុស្សដោយរបៀបណា?
- តើកត្តានេះបំបែកបំបាក់អ្វីនៅក្នុងក្រុមមនុស្ស?
- តើកត្តានេះផ្សាភ្ជាប់អ្វីនៅក្នុងក្រុមមនុស្ស?

យោងតាមប្រភេទ អ្នកអាចចែក កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ទៅជាសមាសធាតុមូលដ្ឋាន ដូច្នេះអ្នកអាចឃើញយ៉ាងច្បាស់ថា អ្នកមានផលជះយ៉ាងណាទៅលើ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។ ការកំណត់កត្តាមួយ ជាកត្តាបែកបាក់ផង និង កត្តាផ្សាភ្ជាប់ផង វាមានការលំបាកក្នុងការកំណត់ឱ្យបានច្បាស់លាស់ថា យើងនឹងផ្លាស់ប្តូរកត្តានោះយ៉ាងដូចម្តេច?

## កម្រិតនៃការវិភាគ

នៅពេលធ្វើការកំណត់ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ចាំបាច់ត្រូវកំណត់ឱ្យបានជាក់លាក់ និងច្បាស់លាស់អំពីកម្រិតនៃការវិភាគរបស់អ្នក។ នៅកម្រិតសហគមន៍មូលដ្ឋាន កត្តាមួយអាចផ្សាភ្ជាប់ក្រុមមនុស្សបានយ៉ាងល្អ។ នៅពេលកម្រិតនៃការវិភាគកាន់តែធំ និង រួមបញ្ចូលក្រុមមនុស្សផ្សេងៗកាន់តែច្រើន កត្តាផ្សាភ្ជាប់ អាចក្លាយជាកត្តាបែកបាក់។

ឧទាហរណ៍៖ ឯករាជ្យភាពរបស់ជនជាតិឃើដ គឺជាកត្តាផ្សាភ្ជាប់ដ៏ខ្លាំងក្នុងចំណោមជនជាតិឃើដ។ ផ្ទុយមកវិញ បើយើងវិភាគលើប្រទេសអ៊ីរ៉ាក់ទាំងមូល ឯករាជ្យភាពរបស់ឃើដ គឺជាកត្តាបែកបាក់រវាងជនជាតិឃើដ និង ប្រជាពលរដ្ឋអ៊ីរ៉ាក់ដទៃទៀត។

ដើម្បីធានាភាពច្បាស់លាស់ ចាំបាច់ត្រូវ**បង្កើតដែនកំណត់ជាក់លាក់**សម្រាប់ការវិភាគ ដើម្បីដឹងថាកត្តាទាំងនេះបែកបាក់ដូចម្តេច? ហើយតើអាចមានផលជះអ្វីក្នុងការពង្រឹង ឬ ធ្វើឱ្យចុះខ្សោយនៃកត្តាមួយ? សម្រាប់ហេតុផលដូចគ្នា ចាំបាច់ត្រូវ**បញ្ជាក់ តើក្រុមណាដែលកំពុងត្រូវបានបំបែកបំបាក់ ឬ ផ្សាភ្ជាប់?** ឧទាហរណ៍៖ ជាជាងការកំណត់ថា ឯករាជ្យភាពរបស់ឃើដ គឺជាកត្តាបែកបាក់ គួរបញ្ជាក់ថា ឯករាជ្យភាពរបស់ឃើដ គឺជាកត្តាបែកបាក់រវាងជនជាតិឃើដ និង ប្រជាពលរដ្ឋអ៊ីរ៉ាក់ដទៃទៀត។

កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ គឺជាឧបករណ៍សម្រាប់កំណត់សមាសភាពនៃបរិបទ ដែលបង្ហាញថា តើក្រុមមនុស្សក្នុងបរិបទពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច? អង្គការដែលធ្វើការក្នុងបរិបទទំនាស់ ដូចជា៖ សកម្មភាពសប្បុរធម៌ និង ជំនួយអភិវឌ្ឍន៍ ត្រូវដឹងថា តើពួកគេនឹងមានផលជះដូចម្តេច លើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។ អង្គការដែលធ្វើការដោយផ្ទាល់លើទំនាស់ ដូចជាការកសាងសន្តិភាព ត្រូវយកចិត្តទុកដាក់លើ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ដើម្បីចៀសវាងធ្វើឱ្យកត្តាទាំងពីរនេះ មានស្ថានភាពកាន់តែអាក្រក់ដោយអចេតនា ទោះបីពួកគេព្យាយាមស្វែងរកមូលហេតុចម្បង នៃទំនាស់ក៏ដោយ។

កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ មានសារៈប្រយោជន៍ក្នុងការស្វែងយល់ពីទំនាស់ហិង្សា ដែលកំពុងកើតមាន ក៏ដូចជាទំនាស់លាក់មុខដែលមិនទាន់មានអំពើហិង្សា។ ទំនាស់លាក់មុខ ក៏អាចមានគ្រោះថ្នាក់ដែរ។ ទំនាស់ទាំងនេះ អ្នកខាងក្រៅមិនងាយនឹងមើលឃើញទេ ប៉ុន្តែចាំបាច់ត្រូវធ្វើការពិនិត្យតាមដាន។ នៅពេលដំណើរការកម្មវិធី យើងនឹងចាប់ផ្តើមមើលឃើញទំនាស់ទាំងនេះ តាមរយៈការកើតឡើងនៃផលជះ។

## សកម្មភាពវិភាគ កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

| ប្រភេទ | ខ្លឹមសារ | លទ្ធផល/សារ |
|---|---|---|
| ការបង្រៀន | ការបង្រៀនអំពីការណែនាំស្តីពីកត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់ ។ ការចែករំលែកបទពិសោធន៍របស់អ្នកបណ្តុះបណ្តាល។ | ការយល់ដឹងជាមូលដ្ឋានអំពីគោលគំនិតនៃកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់។ |
| ការធ្វើសកម្មភាព | <u>ល្បែងកំណត់អត្តសញ្ញាណ៖</u><br>*តម្រូវការ៖ ទីតាំងធំគ្រប់គ្រាន់សម្រាប់សិក្ខាកាមដើរចុះឡើងបាន។*<br>ចែកសិក្ខាកាមជាពីរក្រុមតាមបញ្ជីអត្តសញ្ញាណពីរយ៉ាង (ឧទាហរណ៍៖ ចូលចិត្តកាហ្វេ ឬ តែ) ហើយឈរនៅម្ខាងៗ។ ប្រាប់ពួកគេឱ្យជ្រើសរើស ទីតាំងឈរដោយខ្លួនគេ។ បើមានអ្នក ជ្រើសរើសឈរនៅកណ្តាល នោះជាជម្រើសរបស់គេ។ ជ្រើសរើសបញ្ជីអត្តសញ្ញាណពី៨-១០គូសម្រាប់ល្បែងនេះ។<br>*សម្គាល់៖ ល្បែងនេះអាចពាក់ព័ន្ធនឹងអារម្មណ៍ ឬ នយោបាយ។ សូមជ្រើសរើសបញ្ជីអត្តសញ្ញាណដែលសមស្របនឹងសិក្ខាកាម។* | បន្ទាប់ពីលេងល្បែង ត្រូវឆ្លុះបញ្ចាំងចំណុច២៖<br>១. ជាធម្មតា មនុស្សគ្រប់គ្នានឹងស្ថិតក្នុងក្រុមតែមួយ នៅពេលណាមួយ។<br>២. អ្វីដែលបំបែកបំបាក់ និងផ្សារភ្ជាប់មនុស្សយើង គឺផ្អែកលើអត្តសញ្ញាណ ដែលយើងកំណត់ជាអាទិភាព ក្នុងពេលជាក់លាក់ណាមួយ។ |
| ការសួររកការពិត | <u>ការបង្កើតបរិបទ៖</u><br>▪ ចាប់ផ្តើមជាមួយសំណួរ៖ តើអ្វីផ្សារភ្ជាប់អ្នកជាមួយគ្រួសារ? មិនចាំបាច់កត់ត្រាទុកនូវការឆ្លើយតបឡើយ។ *ជាទូទៅ ចម្លើយមានដូចជា ប្រវត្តិរូប សន្តិសុខ ក្តីស្រលាញ់។*<br>▪ បន្ទាប់មកសួរថា៖ តើអ្វីបំបែកអ្នកចេញពីគ្រួសារ?<br>▪ បន្តសួរថា "តើអ្វីតភ្ជាប់អ្នកទៅនឹង...." និង "តើអ្វីបែកបាក់ចេញពី...." សូមសួរសំណួរនៅគ្រប់កម្រិតខុសៗគ្នា៖ គ្រួសារ អ្នកជិតខាង ខេត្ត ទីក្រុង ប្រទេស។<br>▪ លំហាត់នេះងាយស្រួលអនុវត្តសម្រាប់អ្នកចូលរួមទាំងអស់ ជាពិសេសអ្នកដែលមានបទពិសោធន៍វិភាគតិចតួច។<br>▪ លំហាត់នេះអាចចាប់ផ្តើមមេរៀន ស្តីពីកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ហើយអាចធ្វើមុនបទបង្ហាញ។ | លំហាត់នេះបង្ហាញអំពីគោលគំនិតនៃកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ ដែលធ្វើឱ្យកត្តាទាំងនេះមានភាពច្បាស់លាស់ និងមានលក្ខណៈផ្ទាល់ខ្លួន។ វាជាវិធីល្អក្នុងការណែនាំនូវគំនិតនៃដែនកំណត់ការវិភាគ។ នៅពេលដែលវិសាលភាពនៃការវិភាគកាន់តែធំ ចំនួនក្រុម និងសកម្មភាពមានការផ្លាស់ប្តូរ។ |

| | | |
|---|---|---|
| បទពិសោធន៍ | <u>ការវិភាគករណីសិក្សា</u><br>តម្រូវការ៖ ផ្ទាំងក្រដាសស ហ្វឺត ករណីសិក្សា ចែកករណីសិក្សា ឱ្យសិក្ខាកាមអាន ផ្តោតការយកចិត្តទុកដាក់លើ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។ ក្នុងការពិភាក្សាក្រុមតូច ឬ ពិភាក្សាពេញអង្គ បង្កើតជាបញ្ជី កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។ ជម្រុញសិក្ខាកាមឱ្យឆ្លុះបញ្ចាំងយ៉ាងល្អិតល្អន់លើ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ដែលបានកំណត់ ដើម្បីដឹងថាតួអង្គណាត្រូវបានផ្សាភ្ជាប់ ឬ បែកបាក់យ៉ាងដូចម្តេច?<br>*(សូមមើល កំណត់សម្គាល់បង្រៀនពី ករណីសិក្សា សម្រាប់ព័ត៌មានបន្ថែម)។* | កំណត់ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ នៅក្នុងបរិបទ។ ការប្រើប្រាស់ករណីសិក្សាមួយ អាចមានលក្ខណៈងាយស្រួលជាងការវិភាគបរិបទផ្ទាល់របស់សិក្ខាកាម |
| | <u>កំណត់កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់</u><br>*តម្រូវការ៖ ស្លាយបង្ហាញ ឬ រូបភាពស្តីពីឧបករណ៍មិនបង្កទំនាស់*<br>▪ បង្ហាញស្លាយ ឬ រូបភាពមួយ<br>▪ សួរសិក្ខាកាមតើមានអ្វីកើតឡើងក្នុងរូប? តើពួកគេបានឃើញកត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់ណាមួយដែរឬទេ ?<br>អាចមានការមិនព្រមព្រៀងគ្នា ឬ ការយល់ច្រឡំ។ ធ្វើការពិភាក្សា ។ | លំហាត់នេះបង្ហាញពីការអនុវត្តនូវការកំណត់កត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់ និងពន្យល់ថាតើកត្តាទាំងនេះបែកបាក់ ឬ ផ្សាភ្ជាប់ក្រុមមនុស្សយ៉ាងដូចម្តេច និង ហេតុអ្វី? |

## កត្តាបែកបាក់/កត្តាផ្សាភ្ជាប់ និង ការត្រួតពិនិត្យ វាយតម្លៃ ការរៀនសូត្រ

ការវិភាគលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ នៅក្នុងបរិបទ វានឹងមានការប្រែប្រួលទៅតាមពេលវេលា ហើយវាអាចដាក់បញ្ចូលគ្នាជាផ្នែកមួយនៃផែនការត្រួតពិនិត្យ វាយតម្លៃ និងការរៀនសូត្រ។

ចំណុចសំខាន់ៗរួមមាន៖

- តើយើងគួរធ្វើការតាមដានត្រួតពិនិត្យ កត្តាបែកបាក់/កត្តាផ្សាភ្ជាប់ នៅក្នុងបរិបទដូចម្តេច ដើម្បីដឹងថាតើ កត្តាទាំងនេះកំពុងធ្វើការផ្លាស់ប្តូរទៅតាមលទ្ធផលគម្រោងឬយ៉ាងណា?
- តើការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងបរិបទ ដែលអាចផ្លាស់ប្តូរកត្តាបែកបាក់/កត្តាផ្សាភ្ជាប់ ដែលបានកំណត់នៅក្នុងការវិភាគនេះ?

# ជំហានទី៤៖ ការវិភាគកម្មវិធី

## គោលបំណង

សិក្ខាកាម យល់ដឹងពីសារៈសំខាន់នៃការត្រួតពិនិត្យសេចក្ដីលម្អិតស្ដីពីកម្មវិធីជំនួយរបស់ខ្លួន។ សេចក្ដីលម្អិតទាំងនេះ ជាប្រភពនៃផលជះរបស់ពួកគេ និងប្រភពនៃសណ្ឋានផលជះ ។

## ខ្លឹមសារ ៖ ការវិភាគកម្មវិធី

មេរៀនមួយក្នុងចំណោមមេរៀនដំបូងនៃកម្មវិធីឧបករណ៍មិនបង្កទំនាស់នេះ គឺជាព័ត៌មានលម្អិតស្ដីពីបញ្ហាអន្តរាគមន៍។ ទាក់ទងនឹងផលជះលើកត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់ វាពិតជាកម្រណាស់ ដែលកម្មវិធីមួយធ្វើឲ្យមានផលជះនោះ។ ផ្ទុយទៅវិញ ព័ត៌មានលម្អិតតូចៗនៃកម្មវិធីដែលត្រូវបានរៀបចំឡើងយ៉ាងល្អ និងមានគោលបំណងច្បាស់លាស់ អាចធ្វើឲ្យមានផលជះអវិជ្ជមានដោយអចេតនា។ យើងមើលមិនឃើញពីផលជះទាំងនេះមកលើបរិបទនេះទេ រហូតដល់យើងវិភាគស៊ីជម្រៅលើកម្មវិធីជំនួយ និងភ្ជាប់កម្មវិធីនេះទៅនឹងការវិភាគកត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់របស់យើង។

ភ័ស្តុតាងដែលយើងទទួលបានពីការស្រាវជ្រាវជាក់ស្ដែងបង្ហាញថា មានព័ត៌មានលម្អិតសំខាន់ៗមួយចំនួនស្ដីពីអន្តរាគមន៍ ដែលជាញឹកញាប់ជម្រុញឲ្យមានផលជះលើកត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់។ ក្រៅពីព័ត៌មានលម្អិតទាំងនោះហើយ មានសំណួរ និង មធ្យោបាយស្វែងយល់មួយចំនួនទៀតស្ដីពីកម្មវិធីនេះ ដែលអាចជួយស្ថាប័នមួយ ដឹងច្បាស់ពីផលជះនៃកម្មវិធីជំនួយរបស់ខ្លួន។

ការវិភាគកម្មវិធីមួយ នឹងជួយឲ្យអង្គការនានា ធ្វើការវិភាគស៊ីជម្រៅនូវព័ត៌មានលម្អិតទាំងអស់នៃអន្តរាគមន៍របស់ខ្លួន ដើម្បីឲ្យអង្គការនោះចាប់ផ្ដើមយល់ដឹងពីកម្រិត ដែលព័ត៌មានលម្អិតទាំងនោះមានអន្តរអំពើនឹងគ្នាទៅវិញទៅមកជាមួយនឹងបរិបទនេះ។ ព័ត៌មានលម្អិតទាំងនេះរួមមាន៖

១. ព័ត៌មានលម្អិតនៃ**កម្មវិធី**របស់ខ្លួន (ការជ្រើសរើសអ្នកទទួលផល/សិក្ខាកាម ទីតាំង និងពេលវេលាអនុវត្តកម្មវិធី។ល។)

២. ព័ត៌មានលម្អិតនៃ**ប្រតិបត្តិការ**របស់ខ្លួន (ការជួលបុគ្គលិក លទ្ធកម្ម និង សន្តិសុខ។ល។)

៣. ព័ត៌មានជាក់លាក់នៃ**គោលនយោបាយ**របស់ខ្លួន (ការកំណត់លក្ខណៈ វិនិច្ឆ័យទាំងសម្រាប់កម្មវិធី និងប្រតិបត្តិការ)។

អង្គការជាច្រើន ធ្វើការវិភាគដោយផ្ដោតលើផ្នែកកម្មវិធីមួយចំនួននៃអន្តរាគមន៍របស់ខ្លួនតែប៉ុណ្ណោះ ហើយពុំបានឆ្លុះបញ្ចាំងលើប្រតិបត្តិការ ឬ គោលនយោបាយទេ។ តែប្រតិបត្តិការមានផលជះច្រើន (អង្គការមួយចំនួន អាចនិយាយថាមានផលជះច្រើន) លើសកម្មភាពទំនាស់ដែលជាជម្រើសកម្មវិធី។ ហើយគោលនយោបាយមួយចំនួន ការបង្កើតលក្ខណៈវិនិច្ឆ័យ និងដំណើរការមួយចំនួន ដែលជាមូលដ្ឋាននៃការសម្រេចចិត្ត ទាំងលើកម្មវិធី និងប្រតិបត្តិការ។

## ព័ត៌មានលម្អិតសំខាន់ៗនៃការរៀបចំកម្មវិធី

### តើយើងកំពុងធ្វើការជាមួយនរណា?

នៅពេលនិយាយពីការយកចិត្តទុកដាក់នឹងទំនាស់ ផលជះភាគច្រើនបង្ហាញពីព័ត៌មានលម្អិតស្តីពីនរណា (នរណាដែលនឹង) ទទួលបានផលប្រយោជន៍ពីវត្តមានរបស់ទីភ្នាក់ងារនេះ។ អត្ថប្រយោជន៍ទាំងនេះ ត្រូវបានផ្តល់ជូនតាមរយៈការចូលរួមក្នុងកម្មវិធីដូចជា៖ ការជួល ឬធ្វើកិច្ចសន្យាជាមួយអង្គការ ឬការកំណត់ថាជាដៃគូការងាររបស់អង្គការ។ វាពិតជាសំខាន់ក្នុងការវាយតម្លៃគោលនយោបាយនានាសម្រាប់ភាពជាដៃគូ ការជួលបុគ្គលិក និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសអ្នកទទួលផល ក្នុងបរិបទមួយ ដែលប្រហែលជាបង្កើតនូវភាពលំអៀងជាក់ស្តែង ឬ ភាពលំអៀងនៃការគិត (ឧទាហរណ៍៖ «ឥទ្ធិពលខ្លាំងបំផុត» នៅពេលលក្ខណៈវិនិច្ឆ័យមួយ មានន័យថា ជំនួយនឹងត្រូវបានផ្តល់ទៅកាន់ក្រុមមួយជាមួយនឹងករណីទំនាស់ ពោលគឺ ការបង្កើតឥទ្ធិពលនៃការចែកចាយ)។ គ្រប់សំណួរនៃការវិភាគកម្មវិធីទាំងអស់ បញ្ចប់ដោយការភ្ជាប់ទៅរកពាក្យ (**នរណា**)។

- **បុគ្គលិក** (តើយើងនឹងជួលនរណាឲ្យបម្រើការងារ? ហើយយើងនឹងមិនជួលនរណាឲ្យមកបម្រើការងារ?)
- **អ្នកទទួលផល** (តើនរណាជាអ្នកទទួលផលរបស់យើង និងហេតុអ្វីបានជាពួកគេ ជាអ្នកទទួលផល?)
- **ដៃគូ** (តើទីភ្នាក់ងារផ្សេងទៀត/អង្គភាពរដ្ឋាភិបាលអ្វី ដែលយើងកំពុងចាប់ដៃគូជាមួយ?)
- **អាជ្ញាធរ** (តើយើងកំពុងធ្វើការជាមួយរចនាសម្ព័ន្ធអាជ្ញាធររដ្ឋាភិបាល? ហេតុអ្វី? ហើយតើយើងជ្រើសរើសពួកគាត់ដោយរបៀបណា?)
- តើនរណានឹងត្រូវជ្រើសរើសចេញពីប្រភេទមនុស្សទាំងអស់នេះ?)

### តើយើងនឹងធ្វើការនៅកន្លែងណា?

ការរៀបចំផែនការកម្មវិធីទាក់ទងនឹង **«ទីកន្លែង»** ជាច្រើន។ រាប់ចាប់ពីទីកន្លែង ដែលត្រូវបោះទីតាំងការិយាល័យ រហូតដល់ទីកន្លែងរៀបចំកិច្ចប្រជុំជាមួយនឹងសមាជិកសហគមន៍ ទីកន្លែងការងារ និងកាលានុវត្តភាពផ្សេងៗត្រូវបានផ្សព្វផ្សាយ ទាំងនេះគឺជាបញ្ហាដែលត្រូវចោទសួរ។ ជាថ្មីម្តងទៀត បញ្ហាទាំងនេះបង្ហាញថា តើនរណាដែលត្រូវបានរាប់បញ្ចូល និងតើនរណាដែលត្រូវបានដកចេញពីកម្មវិធី។

- នៅក្នុងទំហំតូច តើការចែកចាយនឹងត្រូវប្រព្រឹត្តទៅនៅកន្លែងណាក្នុងតំបន់ជាក់លាក់មួយ? តើតំបន់នេះអាចផ្តល់លទ្ធភាពឲ្យយើងប្រាស្រ័យទាក់ទងមនុស្សទាំងអស់នៅក្នុងសហគមន៍នេះដែរឬទេ?
- តើបញ្ហាថវិកាមានន័យថា យើងនឹងដកមនុស្សមួយចំនួនចេញពីការរៀបចំកម្មវិធីដែរឬទេ? បើយើងគ្រាន់តែធ្វើទស្សនកិច្ចនៅក្នុងសហគមន៍មួយ ត្រូវចំណាយពេលធ្វើដំណើររយៈពេល ៤ ម៉ោង (ពីការិយាល័យទៅសហគមន៍) តើយើងមានលទ្ធភាពទៅជួបមនុស្សដែលមានតម្រូវការខ្លាំងបំផុតដែរឬទេ?
- តើនរណានឹងត្រូវដកចេញពីកម្មវិធី ដោយសារការជ្រើសរើសទីតាំងរបស់យើង?
- តើការធ្វើបែបនេះ នឹងធ្វើឲ្យយើងឃ្លាតឆ្ងាយពីក្រុមងាយរងគ្រោះដែរឬទេ?

## តើយើងកំពុងធ្វើអ្វី?

នៅពេលយើងគិតអំពី «អ្វី» ចេញពីចក្ខុវិស័យមួយស្ដីពីការយកចិត្តទុកដាក់នឹងទំនាស់ យើងមិនត្រឹមតែកំពុងនិយាយអំពីលទ្ធផល ឬ ផលជះ (ជាក់ស្ដែង និងលទ្ធផលរំពឹងទុក) នៃគម្រោង ឬ កម្មវិធីណាមួយប៉ុណ្ណោះទេ ថែមទាំងធនធានដែលបានប្រើប្រាស់ក្នុងកម្មវិធីនោះផងដែរ។ តើធនធានអ្វីខ្លះដែលយើងត្រូវការ? តើយើងនឹងទទួលបានធនធានទាំងនោះដោយរបៀបណា? ហើយនរណាអាចនឹងទទួលបានផលប្រយោជន៍? ទាំងអស់នេះគឺសុទ្ធតែជា «អ្វី» ដែលត្រូវពិចារណាទាំងអស់។ ពាក្យថា «អ្វី» នេះ ត្រូវការការវិភាគលម្អិតមួយ។ បើយើងកំពុងសាងសង់ សាលារៀនមួយកន្លែង សាលារៀននោះមិនមែនត្រឹមតែជាពាក្យ «អ្វី» ប៉ុណ្ណោះទេ។ គ្រឿងសំណង់ កម្លាំងពលកម្ម ការផ្ដល់ហិរញ្ញប្បទាន ដី និងការសម្រេចចិត្តផ្សេងៗ អំពីអ្វីទាំងអស់នៅខាងលើ គឺសុទ្ធតែជាធនធានក្នុងសហគមន៍ ដែលអាចជាន់គ្នា (បង្កឲ្យមានទំនាស់កាន់តែខ្លាំង) ជាមួយនឹងសកម្មភាពទំនាស់។

- តើប្រភេទអន្តរាគមន៍ (ជំនាញ សេវាកម្ម ទំនិញ។ល។) សមស្របចំពោះបរិបទនេះដែរឬទេ?
- តើមានអ្វីផ្សេងទៀត ដែលយើងអាចផ្ដល់/ធ្វើបានដែរឬទេ?
- តើអ្វីដែលយើងកំពុងផ្ដល់ ឬ កំពុងធ្វើសមស្របសម្រាប់ក្រុមទាំងអស់ក្នុងបរិបទនេះដែរឬទេ?

## តើនៅពេលណាដែលអន្តរាគមន៍របស់យើងនឹងកើតឡើង?

រយៈពេល និងការកំណត់ពេលវេលាសម្រាប់ការរៀបចំកម្មវិធី អាចនឹងត្រូវបានបង្ហាញនៅ **កម្រិតមីក្រូ** (លម្អិតសកម្មភាពតូចៗ) ពេលគឺអាចគិតជាថ្ងៃ សប្ដាហ៍ ឆ្នាំ ដែលកម្មវិធីមួយ ឬ សកម្មភាពមួយចំនួននឹងកើតឡើង ឬនៅ**កម្រិតម៉ាក្រូ** ពេលគឺ នៅពេលដែលទាក់ទងនឹងបរិបទនៃទំនាស់ ដែលអង្គការមួយ ឬកម្មវិធីមួយចូលដល់ ឬកើតមាននៅក្នុងបរិបទមួយ ឬអនុវត្តកម្មវិធីមួយ។ ដើម្បីបង្កើនផលជះវិជ្ជមាន រយៈពេល និង ការកំណត់ពេលវេលា គប្បីសមស្របចំពោះបរិបទ ជាជាងផ្អែកលើឆ្នាំសារពើពន្ធរបស់អង្គការ ឬកាលវិភាគចំណាយរបស់ម្ចាស់ជំនួយ។

- តើយើងកំពុងមកក្នុងពេលវេលាសមស្របដែរឬទេ? ឬ តើយើងកំពុងចាប់ផ្ដើមសកម្មភាពនៅពេលសមស្របដែរឬទេ?
- ក្នុងស្ថានភាពក្រោយសង្គ្រោះបន្ទាន់ ឬ បរិបទក្រោយទំនាស់ តើយើងត្រូវការប្រភេទកម្មវិធីជាក់លាក់មួយដែរឬទេ? តើកម្មវិធីនោះ នឹងរារាំងដល់កិច្ចខិតខំប្រឹងប្រែងស្ដារឡើងវិញ ឬកិច្ចខិតខំប្រឹងប្រែងផ្សះផ្សាដែរឬទេ?
- បើយើងរៀបចំសកម្មភាព ឬ បែងចាយធនធាននៅពេលថ្ងៃត្រង់ តើនរណានឹងមិនអាចចូលរួម ឬមិនអាចទទួលបានសម្ភារៈជំនួយ?
- តើវាជាគំនិតល្អដែរឬទេ ក្នុងការរៀបចំសកម្មភាពក្នុងអំឡុងរដូវភ្លៀង / រដូវប្រាំង / រដូវបង្កបង្កើនផល / រដូវប្រមូលផល? តើនរណាអាចនឹងមិនត្រូវបានរាប់បញ្ចូល ដោយផ្អែកលើរយៈពេលបំពេញការងាររបស់យើង?
- តើយើងមានផែនការសម្រាប់យុទ្ធសាស្ត្រដកខ្លួនចេញដែរឬទេ?

- តើយើងកំពុងផ្តល់កម្មវិធីតែនៅពេលយប់ (នៅពេលដែលស្ត្រីអាចនឹងមិនមានលទ្ធភាពចូលរួម) ឬ? តើយើងកំពុងផ្តល់កម្មវិធីតែនៅពេលថ្ងៃ (នៅពេលដែលពលករ *(ទទួលបានប្រាក់ឈ្នួល ឬ មិនមានប្រាក់ឈ្នួល)* អាចនឹងមិនមានលទ្ធភាពមកចូលរួម) ឬ?

## ហេតុអ្វី និងដោយវិធីណា?

**ហេតុអ្វី និងវិធីណា** គឺជាធាតុផ្សំចម្រុះប្រទាក់ក្រឡាគ្នាចំពោះផ្នែកទាំងអស់នៃកម្មវិធីខាងលើ។ សំណួរទាំងនេះ ពិនិត្យមើល**មូលហេតុ**ចំពោះការសម្រេចចិត្ត ក៏ដូចជា **ដំណើរការ**នៃការធ្វើសេចក្តីសម្រេចចិត្ត ពោលគឺអាស្រ័យលើថាតើ**លក្ខណៈវិនិច្ឆ័យ**ណាមួយ ដែលយើងសម្រេចចិត្តយកជម្រើសនេះ? តើនរណាបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនេះ? តើយើងច្របាច់បញ្ចូលគ្នានូវចក្ខុវិស័យមូលដ្ឋានដោយរបៀបណា?

- នៅពេលយើងសួរខ្លួនឯងថា តើអ្វី? យើងក៏ត្រូវសួរផងដែរថា «ហេតុអ្វីបានជាសម្រេចចិត្តបែបនោះ?» និង «ហេតុអ្វីបានជាមិនសម្រេចចិត្តផ្សេងពីនេះ?»
- នៅពេលយើងសួរខ្លួនឯងថា តើនរណា? យើងក៏ត្រូវសួរផងដែរថា «ហេតុអ្វីបានជាយើង? តើយើងមានជំនាញសមស្រប និងអ្នកជំនាញដែរឬទេ? ឬតើយើងគ្រាន់តែមានប្រាក់តែប៉ុណ្ណោះ?»
- តើយើងនឹងធ្វើកិច្ចការទាំងអស់នេះដោយរបៀបណា? តើយើងនឹងចែកចាយនូវអ្វីដែលយើងបាននាំមកដោយរបៀបណា?
- តើយើងនឹងជ្រើសរើសបុគ្គលិកដោយរបៀបណា?
- តើយើងនឹងដឹងដោយរបៀបណាថានៅពេលណា នឹងត្រូវបញ្ចប់ដោយមាន អន្តរាគមន៍របស់យើង?
- តើនរណាចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់យើង? តើយើងបានផ្តល់ឲ្យក្រុមទាំងអស់នូវលទ្ធភាពចូលរួមក្នុងដំណើរការសម្រេចចិត្តទាំងនេះដែរឬទេ?
- តើសេចក្តីសម្រេចចិត្តទាំងនេះមានតម្លាភាពចំពោះសហគមន៍កម្រិតណា?
- តើបុគ្គលិកទាំងអស់ពន្យល់ពីតម្លាភាពបានដែរឬទេ?

ការបង្ហាញនូវព័ត៌មានលម្អិតទាំងអស់នៃកម្មវិធីជំនួយមួយ មិនត្រឹមតែផ្តល់លទ្ធភាព ឲ្យអ្នកមើលឃើញពីទីកន្លែង ដែលអន្តរាគមន៍របស់យើងនឹងមានផលជះលើ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ (បើអ្នកនឹងជួលបុគ្គលិកពីក្រុមការងារតែមួយ។ ឧទាៈ ការធ្វើបែបនេះ អាចផ្តល់ឲ្យអ្នកនូវតម្រុយនៅក្នុងកត្តាបែកបាក់ដែលបានកើនឡើងប្រកបដោយសក្តានុពល) ប៉ុណ្ណោះទេ វាថែមទាំងជួយអ្នកឲ្យមានតម្លាភាព និងបង្ហាញពីដំណើរការ ធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកទៅកាន់ដៃគូ អ្នកទទួលផល បុគ្គលិក និងអ្នកមិនបានទទួលផលដូចគ្នាផងដែរ។

ដំណឹងល្អអំពីកម្មវិធីជំនួយ គឺថាព័ត៌មានលម្អិតសំខាន់ៗភាគច្រើន អាចនឹងត្រូវបានសម្របសម្រួល ឬ កែតម្រូវឲ្យសមស្របទៅតាមបរិបទដោយគ្មានការផ្លាស់ប្តូរអាណត្តិ ឬ រចនាសម្ព័ន្ធរបស់អង្គការ និងដោយមិនតម្រូវឲ្យមានការផ្តល់មូលនិធិបន្ថែមច្រើននោះទេ។ ជាក់ស្តែង កម្មវិធីឧបករណ៍មិនបង្កទំនាស់ បានមើលឃើញថា ជាញឹកញាប់បានធ្វើការកែតម្រូវទៅតាមកម្មវិធីជំនួយមួយ ដែលអាចសន្សំសំចៃថវិការបស់អង្គការ ។ បើមិនដូច្នេះទេ វានឹងត្រូវបានចំណាយលើការកាត់បន្ថយផលជះអវិជ្ជមាន។

## កត្តាគម្រាមកំហែង

ពិតណាស់យើងតែងតែមានផ្នែកលម្អិតមួយចំនួន ដែលយើងមិនមានសិទ្ធិធ្វើការកែតម្រូវ ។ ការសម្រេចចិត្តនានា ត្រូវបានធ្វើឡើងនៅ **ការិយាល័យកណ្តាល** របស់ទីភ្នាក់ងារនៅក្រៅប្រទេស **គោលនយោបាយ** មួយចំនួន ឬ លក្ខណៈវិនិច្ឆ័យ ត្រូវបានកំណត់ដោយ **ម្ចាស់ជំនួយ** ឬ កម្មវិធីត្រូវបានកំណត់នៅក្នុងដែនអនុវត្តរបស់ខ្លួន ដោយសារ **អាណត្តិ** របស់អង្គការ។

កត្តាទាំងនេះអាចដាក់កម្រិតដល់ទីភ្នាក់ងារមួយ ឬ កំណត់សមត្ថភាពរបស់កម្មវិធី ដើម្បីជ្រើសរើសបានយ៉ាងល្អនូវជម្រើសនៃការយកចិត្តទុកដាក់នឹងទំនាស់។ ទោះជាយ៉ាងនេះក្តី ការយកចិត្តទុកដាក់នឹងទំនាស់ និងកម្មវិធីឧបករណ៍មិនបង្កទំនាស់ ជានិច្ចកាលមិនមានន័យថាជាការសម្រេចចិត្តដ៏ល្អបំផុតនោះទេ។ ផ្ទុយទៅវិញ វាមានន័យថា ការដឹងពីផលវិបាកនៃជម្រើសជាក់លាក់ណាមួយ ហើយបន្ទាប់មក ធ្វើការសម្របសម្រួលកម្មវិធីមួយ ប្រតិបត្តិការរបស់ទីភ្នាក់ងារ ឬ គោលនយោបាយ ដើម្បីឲ្យមានផលជះវិជ្ជមានច្រើនបំផុតដែលអាចកើតឡើងលើសកម្មភាពទំនាស់។

## សកម្មភាព

| ប្រភេទ | ខ្លឹមសារ | លទ្ធផល/សារ |
|---|---|---|
| ការបង្រៀន | ការបង្រៀនណែនាំស្តីពីការវិភាគកម្មវិធី ។ បទពិសោធន៍របស់អ្នកបណ្តុះបណ្តាល។ | ការយល់ដឹងជាមូលដ្ឋានពីវិធី និងមូលហេតុដែលយើងធ្វើការវិភាគកម្មវិធី។<br>ឧទាហរណ៍ស្របតាមបរិបទ។ |
| ការធ្វើសកម្មភាព | | |
| ការសួររកការពិត | | |
| បទពិសោធន៍ | **ការវិភាគករណីសិក្សា**<br>សម្ភារៈ៖ ផ្ទាំងក្រដាសស ហ្វឺត ករណីសិក្សា<br>ការប្រើប្រាស់ករណីសិក្សាបង្រៀន ស្នើឲ្យសិក្ខាកាមស្វែងយល់ពីសណ្ឋានផលជះ ដែលត្រូវបានបង្ហាញដោយអង្គការក្នុងករណីសិក្សានេះ។ (សូមមើលឯកសារបង្រៀនករណីសិក្សាសម្រាប់ព័ត៌មានបន្ថែម) | ការស្វែងយល់ពីសណ្ឋានផលជះក្នុងបរិបទ។<br>ការយល់ដឹងជាមូលដ្ឋានពីវិធី និងមូលហេតុ ដែលយើងធ្វើការវិភាគកម្មវិធី។<br>ឧទាហរណ៍ស្របតាមបរិបទ។ |

## ការវិភាគ និងការពិនិត្យតាមដានកម្មវិធី វាយតម្លៃ និងការរៀនសូត្រ

- តើយើងកំពុងព្រមព្រៀងគ្នាពីគុណភាពនៃការរៀបចំកម្មវិធីរបស់យើងផ្ទាល់តាមរយៈការមិនយកចិត្តទុកដាក់លើផលជះនៃទំនាស់របស់យើងដែរឬទេ?
- តើនរណានឹងតាមដានព័ត៌មានលម្អិតរបស់កម្មវិធី ហើយនៅពេលណា?
- តើយើងកំពុងប្រើប្រាស់ទ្រឹស្តីនៃការផ្លាស់ប្តូររបស់យើង ខណៈយើងបានរៀនសូត្រអំពីផលជះដែលព័ត៌មានលម្អិតស្តីពីកម្មវិធីរបស់យើង កំពុងមានក្នុងបរិបទនេះដែរឬទេ?

## ជំហានទី៥៖ សណ្ឋានផលជះ ( Parterns of Impact )

### គោលបំណង

ធ្វើការណែនាំអំពីរបៀបដែលកម្មវិធីផ្តល់ជំនួយមានទំនាក់ទំនងជាមួយបរិបទ។ ឧបករណ៍មិនបង្កទំនាស់ បានកំណត់សណ្ឋានច្បាស់លាស់តាមរយៈទំនាក់ទំនងទាំងនេះ។ ការកំណត់សណ្ឋានជាវិជ្ជមាន ឬ អវិជ្ជមាន មានជំហានក្នុងការផ្លាស់ប្តូរ ឬ ជម្រុញបន្ថែម គឺផ្អែកលើមូលដ្ឋាននៃការរៀបចំ និង អនុវត្តកម្មវិធីការយកចិត្តទុកដាក់នឹងទំនាស់។

### ខ្លឹមសារមេរៀន៖ សណ្ឋាននៃផលជះ

ភស្តុតាងបានមកពី ការអនុវត្តឧបករណ៍មិនបង្កទំនាស់ ជាមួយទីភ្នាក់ងារនានាដែលផ្តល់ជំនួយគ្រប់ប្រភេទក្នុងបរិបទទំនាស់ បានរកឃើញថា មានសណ្ឋានច្បាស់លាស់ ដែលកម្មវិធីជំនួយមានផលជះទាំង វិជ្ជមាន និង អវិជ្ជមាន លើបរិបទដែលពួកគេធ្វើការ។ យើងអាចមើលឃើញទុកជាមុនថា **តើជំនួយនឹងមានទំនាក់ទំនងជាមួយទំនាស់ដូចម្តេច?** យើងអាចគិតអំពីវិធីដែលបញ្ចៀសនូវផលជះអវិជ្ជមាន និង ពង្រឹងផលជះវិជ្ជមាន ។ សណ្ឋានទាំងនេះមានលក្ខណៈសកល និង បានមកពីបទពិសោធន៍តាមមូលដ្ឋានរបស់ទីភ្នាក់ងារនានា ដែលធ្វើការក្នុងបរិបទខុសៗគ្នា។

១. **សកម្មភាព** របស់ស្ថាប័ន៖
- ក. **អ្វី?** ផលិតផល និង សេវា ដែលស្ថាប័នផ្ទេរទៅក្នុងបរិបទអាចធ្វើឱ្យមានការកើនឡើង ឬ ថយចុះសមភាព និង សុវត្ថិភាពក្នុងបរិបទ។
- ខ. **របៀបណា?** យន្តការដែលប្រើដើម្បីផ្ទេរផលិតផល និង សេវា អាចមានឥទ្ធិពលខ្លាំងលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់។

២. **អាកប្បកិរិយា** បុគ្គល ឬ ក្រុម៖
- ក. **របៀបណា?** របៀបទំនាក់ទំនងរវាងបុគ្គលិក និង បុគ្គលិក ជាមួយអង្គការ/ស្ថាប័នដទៃទៀត និង ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន គឺជាការផ្ញើសារអំពីគោលបំណង គុណតម្លៃ និង គោលដៅរបស់ពួកគេ។

វាមានសារៈសំខាន់ណាស់ក្នុងការសម្គាល់ថា សណ្ឋាននៃសកម្មភាព និង អាកប្បកិរិយា អាចមានទាំងភាពវិជ្ជមាន និង អវិជ្ជមាន។ អង្គការ/ស្ថាប័នដែលមិនធ្វើការត្រួតពិនិត្យបានទៀងទាត់លើបរិបទ ឬ ខកខានមិនបានភ្ជាប់កម្មវិធីរបស់ពួកគេទៅនឹងការវិភាគបរិបទ នឹងទទួលរងផលជះអវិជ្ជមាន ដោយមិនដឹងខ្លួន ខណៈដែលអង្គការមានយុទ្ធសាស្ត្រត្រួតពិនិត្យទៀងទាត់ក្នុងបរិបទ ធ្វើការឆ្លើយតបចំពោះការផ្លាស់ប្តូរទាំងនេះ ហើយបង្កើតជាសណ្ឋានវិជ្ជមាន។

### ផលជះលើការផ្ទេរធនធាន/សកម្មភាព

គ្រប់កម្មវិធីធ្វើការផ្ទេរធនធាន អាចជារូបិយ ឬ អរូបិយ ទៅក្នុងបរិបទនៃតំបន់ធ្វើការរបស់ខ្លួន។ ធនធានទាំងនេះរួមមាន៖ ថវិកា ផលិតផល ជំនាញ អាហារ ជម្រក និង ការតស៊ូមតិ។ ការផ្ទេរធនធានគឺជាសកម្មភាពអង្គការ។ យើងត្រូវចងចាំថា៖ នៅពេលមានធនធានពីខាងក្រៅចូលក្នុងតំបន់ដែលខ្វះ

ធនធាន ធ្វើឱ្យមនុស្សមានទំនាស់ជាមួយគ្នា ហើយប្រជាពលរដ្ឋមូលដ្ឋាន នឹងមើលឃើញធនធានទាំងនេះ ថាជាអំណាច និង ទ្រព្យសម្បត្តិ។ ហេតុដូច្នេះ ធនធានក្លាយជាផ្នែកនៃទំនាស់។ មនុស្សស្ថិតក្នុងទំនាស់ នឹងមានបំណងចង់គ្រប់គ្រង និង ប្រើធនធានជំនួយ ដើម្បីគាំទ្រភាគី/ក្រុមរបស់ខ្លួនតែប៉ុណ្ណោះ និង ធ្វើឱ្យភាគីម្ខាងទៀតទន់ខ្សោយ។ ផលជះនៃការផ្ទេរទាំងនេះ កើតមានឡើងក្នុងរូបភាពចំនួន ៥ គឺ៖

### ១. ឥទ្ធិពលនៃការបង្វែរធនធាន

ទំនិញ ឬ ថវិកា ដែលគ្រោងសម្រាប់ចែកចាយ ឬ យកទៅចំណាយលើអ្វីមួយ អាចត្រូវបានគេលួច និង ប្រើប្រាស់ដោយភាគីទំនាស់។ ទំនិញ ឬ ថវិកា អាចត្រូវបានប្តូរ ឬ (បង់ពន្ធ) ជាមូលនិធិសម្រាប់ទំនាស់/សង្គ្រាមដែលកំពុងកើតមាន។









## ២. ឥទ្ធិពលទីផ្សារ

ក្នុងបរិយាកាសទំនាស់ហិង្សា ជំនួយមានផលជះលើតម្លៃ ប្រាក់បៀវត្សរ៍ និង ប្រាក់ចំណេញ និង អាចពង្រឹងសង្គ្រាមសេដ្ឋកិច្ច ដោយការបង្កើនសកម្មភាព និង មនុស្សដែលពាក់ព័ន្ធនឹងសង្គ្រាម។ គ្រប់បរិយាកាសទាំងអស់ ការកើនឡើងតម្លៃរបស់ទំនិញ និង សេវាកម្ម អាចឲ្យតម្លៃខ្ពស់ដល់ប្រជាពលរដ្ឋមូលដ្ឋាន ធ្វើឲ្យទីផ្សារមូលដ្ឋានផ្លាស់គ្មានប្រភេទទំនិញទាំងនេះសម្រាប់លក់។ ទីភ្នាក់ងារក៏អាចមាន ផលជះលើទីផ្សារ ដោយការនាំយកទំនិញ និង សេវាកម្មពីខាងក្រៅ ដែលទំនិញទាំងនោះអាចរកបាននៅក្នុងសហគមន៍មូលដ្ឋាននេះស្រាប់ ហើយផ្តល់វាដោយឥតគិតថ្លៃ។ ប្រការនេះ ធ្វើឱ្យធ្លាក់ចុះតម្លៃទំនិញតាមមូលដ្ឋាន និង អាចបង្ខំកសិករ និង អ្នកលក់ឱ្យស្វែងរកការងារថ្មី (ភាគច្រើនគឺក្នុងកំឡុងពេលមានសង្គ្រាម)។




## ៣. ឥទ្ធិពលនៃការចែកចាយ

ការចែកចាយទំនិញ ប្រាក់កាស ឬ ឱកាស ក្នុងអំឡុងពេលកើតមានទំនាស់ស្រាប់ អាចកាន់តែធ្វើឱ្យមានសម្ពាធកាន់តែខ្លាំង និងកត្តាបែកបាក់កាន់តែមានភាពធ្ងន់ធ្ងរឡើង ដោយការផ្តល់ផលប្រយោជន៍មិនស្មើភាពដល់ភាគីទាំងអស់ (ភាគីម្ខាងបានប្រយោជន៍ច្រើនជាងភាគីម្ខាងទៀត)។



## ៨. ឥទ្ធិពលនៃការជំនួស

នៅពេលខ្លះ អង្គការដើរតួនាទីជំនួសឲ្យរដ្ឋាភិបាល (ឧទាហរណ៍៖ ការកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិ)។ ការជំនួស គួរតែមានយុទ្ធសាស្រ្ត រយៈពេលខ្លី និងមានការជជែកជាមួយរដ្ឋាភិបាល។ ហើយរដ្ឋាភិបាល គួរចូលរួមក្នុងការរៀបចំកម្មវិធីនេះ ដូច្នេះ ពួកគេនឹងបានដឹងពីការទទួលខុសត្រូវលើតួនាទីរបស់ខ្លួន រួមទាំងការផ្ទេរការទទួលខុសត្រូវ និងការបង្កើតក្របខណ្ឌពេលវេលា និងយុទ្ធសាស្រ្តមានស្រាប់ ដើម្បីជួយធានាថា សមត្ថភាពគ្រប់គ្រងនាពេលអនាគតត្រូវបានពង្រឹង។ ការជំនួស ប្រហែលជាធ្វើឲ្យចុះខ្សោយនូវសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតប និង គ្រប់គ្រងគ្រោះមហន្តរាយ និង ទំនាស់ ព្រមទាំងការអភិវឌ្ឍខ្លួនឯងផ្ទាល់។






## ៩. ឥទ្ធិពលទទួលស្គាល់

អង្គការ អាចធ្វើឱ្យមានភាពស្របច្បាប់ជាយថាហេតុដល់រដ្ឋាភិបាល អ្នកដឹកនាំ ឬ ស្ថាប័ន ដោយបញ្ចូលរដ្ឋាភិបាលទៅក្នុងដំណើរការផ្តល់ជំនួយ (ការចែកចាយ ចេញផ្សាយជាសាធារណៈ...) ។ ប្រការនេះ ធ្វើឲ្យមានបញ្ហាជាលក្ខណៈប្រព័ន្ធ នៅពេលដែលវាផ្តល់ភាពស្របច្បាប់ទៅដល់រដ្ឋាភិបាល មេដឹកនាំ ឬ ស្ថាប័ន ដែលចាត់ទុកថា ទទួលខុសត្រូវក្នុងអំពើហិង្សា ឬ អាកប្បកិរិយាមិនស្មើភាព។

យើងអាចធ្វើបាន ដើម្បីចៀសផុតពីផលជះអវិជ្ជមាន ក្នុងរូបភាពទាំង៥ យ៉ាងនេះ និង ទទួលបានផលជះវិជ្ជមានលើបរិបទ ដោយរៀបចំកម្មវិធីភ្ជាប់ទៅនឹងការវិភាគបរិបទរបស់អ្នក អនុញ្ញាតឲ្យមានវិធីសាស្រ្តថ្មី មានការទទួលខុសត្រូវស្មើភាពគ្នា និងផែនការយុទ្ធសាស្រ្តសម្រាប់កម្មវិធីនាពេលអនាគត




## សណ្ឋានអាកប្បកិរិយាជាវិជ្ជមាន

វាអាចធ្វើទៅបានសម្រាប់ភ្នាក់ងារផ្តល់ជំនួយ ដើម្បីឲ្យមានផលជះវិជ្ជមានទៅលើបរិបទទំនាស់ ទោះបីជាសណ្ឋាននៃការចែកចាយធនធានរបស់ពួកគេ និងទោះបីជាតម្រូវឱ្យមានការគិតគូរជាយុទ្ធសាស្ត្រមួយចំនួន ការវិភាគឲ្យបានល្អមួយដែលត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ទៅលើបរិបទ និងជម្រើសកម្មវិធី។ ការធ្វើការងារដោយប្រើយុទ្ធសាស្ត្រទាំងនេះ អាចមានប្រសិទ្ធភាពទៅលើរបៀបវារៈធំៗរបស់ភ្នាក់ងារផ្តល់ជំនួយ និងពង្រឹងទៅលើផលជះរបស់ពួកគេនៅក្នុងវិស័យដទៃទៀត។ ក្នុងករណីខ្លះ ការប្រើយុទ្ធសាស្ត្រទាំងនេះ ជួនកាលអាចបង្កឲ្យមានទំនាស់ជាមួយនឹងមុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័នមួយ (ដោយមានវិធានការណ៍បង្ការកុំឲ្យមានការលួច ឬ ការបង្វែរធនធាន - មនុស្សគប់គ្នាគួរធ្វើការដើម្បីបង្ការកុំឲ្យមានការលួច ឬ ការបង្វែរធនធានខុសគោលដៅ) ។

### ១. ឥទ្ធិពលនៃការបង្វែរធនធាន ឬ ការបង្ការការលួច

មានធាតុផ្សំ ៤យ៉ាង ដើម្បីឲ្យនរណាម្នាក់អាចលួចអ្វីមួយបាន

- ចំណេះដឹង៖ ពួកគេត្រូវតែដឹងថា មានអ្វីមួយដើម្បីលួច របស់នោះវានៅឯណា និងត្រូវយកវាដោយរបៀបណា....
- គុណតម្លៃ៖ វត្ថុដែលនឹងត្រូវលួច ត្រូវតែមានតម្លៃនៃភាពប្រថុយប្រថានក្នុងការលួច
- និទន្តភាព៖ ពួកគេត្រូវដឹងថាពួកគេអាចលួចវាចេញទៅបាន
- ឱកាស៖ ពួកគេត្រូវការឱកាសដើម្បីលួចវា

ប្រសិនបើបាត់បង់ចំណុចណាមួយក្នុងធាតុផ្សំទាំងបួន អ្នកនឹងអាចកាត់បន្ថយការប៉ុនប៉ង ហើយវានឹងអាចបំបាត់ការប៉ុនប៉ង ប្រសិនបើអ្នកបាត់បង់ធាតុផ្សំទាំងនេះលើសពីមួយ។ គំនិតច្នៃប្រឌិត និងដំណោះស្រាយសម្រាប់បរិបទជាក់លាក់មួយ គឺអាចជួយបានយ៉ាងល្អបំផុត។ បង្ការការលួច គឺមានន័យ

ថារក្សាធនធានពីការប្រើប្រាស់ខុសគោលដៅ ហើយក្លាយទៅជាទំនាស់ ឬ ទំនាស់ផលប្រយោជន៍ និង ជួយសន្សំសំចៃធនធានទាំងនេះ ដើម្បីប្រើប្រាស់ក្នុងគោលបំណងសន្តិភាព។

### ២. ឥទ្ធិពលទីផ្សារ

ភ្នាក់ងារផ្តល់ជំនួយមានអំណាចក្នុងការជម្រុញ និងរក្សាលំនឹងទីផ្សារសម្រាប់ទំនិញ និងសេវាកម្មក្នុងតំបន់ ដើម្បីពង្រឹងសេដ្ឋកិច្ចស៊ីវិល និងដើម្បីធានាថាប្រជាជនមូលដ្ឋាននៅតែអាចចូលរួមទីផ្សារក្នុងតំបន់។ ទីភ្នាក់ងារផ្តល់ជំនួយចាំបាច់ត្រូវធ្វើការវិភាគពីទីផ្សារក្នុងស្រុក ដើម្បីកំណត់ថា ទំនិញ និងសេវាកម្មអ្វីខ្លះ ដែលត្រូវបានលក់នៅទីនោះ។ ហើយនិងរបៀបដែលទីផ្សារក្នុងស្រុក អាចត្រូវទទួលរងផលប៉ះពាល់ដោយអន្តរាគមន៍របស់ភ្នាក់ងារផ្តល់ជំនួយ និងរបៀបដែលវាអាចជះឥទ្ធិពលដល់កត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់។ ជាទូទៅ គឺមានជម្រើសសម្រាប់ការស្វែងរកទំនិញមូលដ្ឋាន ដើម្បីគាំទ្រដល់អ្នកដាំដុះ អ្នកផលិត និង អ្នកលក់ក្នុងស្រុក។

### ៣. ឥទ្ធិពលនៃការចែកចាយ

ដោយមានការយល់ដឹងពីអ្វីទៅជាមូលដ្ឋាន និងនិយមន័យជាក់លាក់របស់វា គឺសម្រាប់ការចែកចាយដោយយុត្តិធម៌ (Fair Distribution) នៅក្នុងបរិបទ (បច្ចុប្បន្ននេះ ការយល់ដឹងគឺជាគន្លឹះសំខាន់ ដោយយោងទៅលើសកម្មភាពទំនាស់បច្ចុប្បន្ន)។ ភ្នាក់ងារផ្តល់ជំនួយ អាចចែកចាយទំនិញ និងសេវាកម្ម ទៅប្រជាជនគោលដៅរបស់ខ្លួន ដោយមិនបង្កឲ្យមានទំនាស់ប៉ុណ្ណោះទេ ថែមទាំងអាចពង្រឹងកត្តាផ្សាភ្ជាប់ទៀតផង។ ការចែកចាយដោយយុត្តិធម៌ ជានិច្ចកាល គឺមិនមែនជាការចែកចាយដោយមានភាព (ស្មើគ្នា) នោះទេ។ សួរទៅកាន់ប្រជាជនមូលដ្ឋានថា តើអ្វីជាយុត្តិធម៌?

តម្លាភាពពីគោលដៅគម្រោង គឺសំខាន់បំផុតដើម្បីទទួលបានទំនុកចិត្តពីប្រជាជនមូលដ្ឋាន នៅពេលធ្វើការចែកចាយឆ្លងកាត់ខ្សែបន្ទាត់ទំនាស់មួយ។

### ៤. ឥទ្ធិពលនៃការជំនួស

ជួនកាល វាមានភាពចាំបាច់សម្រាប់អង្គការផ្តល់ជំនួយ ដើម្បីជំនួសការទទួលខុសត្រូវរបស់រដ្ឋាភិបាលមួយ (ក្នុងកំឡុងពេលគ្រោះធម្មជាតិ ឬវិបត្តិ)។ ការជំនួស គួរតែត្រូវធ្វើឡើងជាលក្ខណៈយុទ្ធសាស្ត្ររយៈពេលខ្លី និងដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល។ រដ្ឋាភិបាលគួរចូលរួមក្នុងការរៀបចំកម្មវិធី ដូច្នេះពួកគេនឹងយល់ និងមានការទទួលខុសត្រូវសម្រាប់តួនាទីរបស់ពួកគេ រួមមាន៖ ការផ្ទេរតួនាទី និងការបង្កើតគម្រោងពេលវេលា និងយុទ្ធសាស្ត្រក្នុងការដកចេញ ដើម្បីធានាថាសមត្ថភាពអភិបាលនាពេលអនាគតនឹងត្រូវបានពង្រឹង។

### ៥. ឥទ្ធិពលទទួលស្គាល់

ភ្នាក់ងារផ្តល់ជំនួយ អាចធ្វើឲ្យមានស្របច្បាប់ជាលក្ខណៈយុទ្ធសាស្ត្រ និងមានគោលបំណងដល់រដ្ឋាភិបាល មេដឹកនាំ ឬស្ថាប័នមួយ ដែលមានគោលដៅនៃការផ្លាស់ប្តូរ ឬធ្វើអោយប្រសើរឡើងនូវការគិត ឬទស្សនរបស់ប្រជាជនមូលដ្ឋាន និងសមត្ថភាពរបស់អង្គភាពក្នុងការគាំទ្រ ឬដើម្បីឆ្លើយតបទៅនឹងតំរូវ

ការចាំបាច់។ ប្រការនេះ ក៏អាចធ្វើឲ្យមានឥទ្ធិពលទៅលើការបង្កើតនូវតម្រូវការគណនេយ្យភាពបន្ថែមទៀត ស្តីពីការអភិបាលកិច្ចមូលដ្ឋាន។ ដើម្បីធ្វើដូចនេះ វាមានសារៈសំខាន់ក្នុងការស្វែងយល់ពី (**របៀប** និង **ហេតុអ្វី**) អង្គភាពមួយ នឹងត្រូវទទួលបានភាពស្របច្បាប់ នៅកន្លែងដែលអាចទទួលបានការឆ្លើយតបអវិជ្ជមានពីប្រជាជនក្នុងស្រុក និង របៀបដែលភ្នាក់ងារផ្តល់ជំនួយកំពុងធ្វើ ត្រូវបានមើលថាកំពុងចូលរួមក្នុងសកម្មភាពទំនាស់នាពេលបច្ចុប្បន្ន។

ដើម្បីទទួលបានផលជះវិជ្ជមានមួយក្នុងចំណោមផលជះទាំង ៥ គឺជាវិធីមួយដើម្បីបង្កើតគុណតម្លៃបន្ថែមសម្រាប់ការងារផ្តល់ជំនួយ និងកសាងទំនាក់ទំនងវិជ្ជមានក្នុងសហគមន៍មូលដ្ឋាន។ ទោះយ៉ាងណាក៏ដោយ ភ្នាក់ងារផ្តល់ជំនួយ ចង់ធ្វើឱ្យមានតុល្យភាពទីផ្សារ ការចែកចាយដោយយុត្តិធម៌ ការជំនួសការងារមួយផ្នែករបស់រដ្ឋាភិបាលក្នុងរយៈពេលខ្លី ឬផ្តល់ស្របច្បាប់ជាលក្ខណៈយុទ្ធសាស្ត្រដល់មេដឹកនាំមួយ **<u>ត្រូវតែធ្វើការវិភាគជាទៀងទាត់</u>** ពីផលជះនៃការងារទាំងនេះ ។ យើងមិនអាចព្យាករណ៍ពី ផលវិបាកដែលយើងមិនចង់បាន ចេញពីប្រភេទសកម្មភាពទាំងនេះ ហើយភ្នាក់ងារផ្តល់ជំនួយ ត្រូវតែត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតប ប្រសិនបើបរិបទឆ្លើយតបជាអវិជ្ជមានទៅនឹងធាតុផ្សំណាមួយរបស់កម្មវិធី ។ ដោយភាពចាំបាច់ ការងារទាំងនេះ ត្រូវបានផ្អែកលើបរិបទមូលដ្ឋាន។

កម្មវិធីអាចធ្វើការនៅតំបន់ផ្សេងទៀត ប៉ុន្តែពួកគេអាចមានលទ្ធផលខុសគ្នាទាំងស្រុង ប្រសិនបើមានបរិបទថ្មីមួយចូលមកដល់ ដោយគ្មានការយល់ដឹងពេញលេញពីផលជះដែលនឹងអាចកើតមាន។

## សារបង្កប់ន័យក្រមសីលធម៌ / អាកប្បកិរិយា

វិធីទីពីរដែលអង្គការមានផលជះលើបរិបទ គឺតាមរយៈអាកប្បកិរិយា បង្ហាញដោយបុគ្គលិក។ អាកប្បកិរិយារបស់បុគ្គលិក ផ្តល់សារអំពីគុណតម្លៃ និង គោលបំណងរបស់ពួកគេ។ ជាញឹកញាប់ អាកប្បកិរិយារបស់មនុស្សម្នាក់ គឺជាសូចនាករដែលបង្ហាញពីគោលបំណងរបស់ពួកគេ ជាងពាក្យសម្តី។ យើងតែងតែផ្ញើសារតាមរយៈសកម្មភាពរបស់យើង ហើយអ្នកផ្សេងទៀតតែងតែទទួលសារនេះ។ សាររបស់យើង អាចពង្រឹងនូវអារម្មណ៍ និង លក្ខណៈទំនាស់បែបបំផ្លាញ ឬ សារទាំងនេះអាចលើកកម្ពស់សីលធម៌ ដែលពង្រឹង និង ជម្រុញឲ្យមានការនៅរស់នៅជាមួយគ្នាដោយសន្តិភាព។
សណ្ឋាននៃអាកប្បកិរិយាចែកចេញជា ៤ ប្រភេទគឺ៖

### ១. ការគោរព

ទំនាក់ទំនងជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋានដោយមានការគោរពគ្នាទៅវិញទៅមក គឺមានភាពស្ងប់ស្ងាត់ សហការ ទំនុកចិត្ត និងយកចិត្តទុកដាក់ចំពោះក្តីកង្វល់ក្នុងមូលដ្ឋាន។ ការប្រាស្រ័យទាក់ទងដោយគ្មានការគោរព គឺមានភាពសង្ស័យ ភាពខុសគ្នា ការឈ្លានពាន ឬ មិនឲ្យតម្លៃ។ ការប្រាស្រ័យទាក់ទង ដោយមានការគោរព មានភាពបើកចំហ និង លើកទឹកចិត្តឲ្យមានការផ្តល់នូវយោបល់ត្រឡប់ និង តវ៉ាផងដែរ។ ទំនាក់ទំនងគ្មានការគោរព ផ្តល់ព័ត៌មានដោយមិនបើកឱ្យមានការផ្តល់ជាយោបល់ត្រឡប់ និង បង្ហាញដំណោះស្រាយ ដែលមិនមានក្នុងបរិបទ។






## ២. គណនេយ្យភាព/ការទទួលខុសត្រូវ

អង្គការ និង បុគ្គលិក បង្ហាញគណនេយ្យភាពនៃសកម្មភាព និង ការសម្រេចចិត្តរបស់ខ្លួន ដោយៈ ការធ្វើសកម្មភាពជាជាងការបង្ហាញនូវភាពគ្មានអំណាច ការទទួលខុសត្រូវសម្រាប់កំហុសឆ្គងជាជាង ការបង្ហាញនិទណ្ឌភាព ការអនុវត្តតាមវិធានច្បាប់ជាជាងការប្រើអាវុធដើម្បីបង្ហាញអំណាច។

ជាញឹកញាប់ គណនេយ្យភាព សំដៅទៅលើថ្នាក់លើដូចជាៈ ទីស្នាក់ការកណ្តាល ម្ចាស់ជំនួយ និង អង្គការ/ស្ថាប័នគ្រប់គ្រងកម្រិតខ្ពស់ ។ ទោះបីយ៉ាងណា គណនេយ្យភាពនៅទីនេះ សំដៅលើ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងការឆ្លើយតបចំពោះក្តីកង្វល់តាមមូលដ្ឋាន ។ ប្រសិនបើ បុគ្គលិកមិន ទទួលខុសត្រូវលើកំហុសឆ្គងរបស់ខ្លួន ឬ មិនចាត់វិធានការដែលចាំបាច់ ប្រជាពលរដ្ឋក្នុងមូលដ្ឋាននឹង បាត់បង់ទំនុកចិត្តចំពោះអង្គការទាំងមូល ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។





## ៣.ភាពត្រឹមត្រូវ / ស្មើភាព

សណ្ឋាននៃអាកប្បកិរិយា ដែលមានភាពយុត្តិធម៌ ត្រឹមត្រូវ និងស្មើភាព ទទួលស្គាល់នូវតម្លៃនៃ ការចូលរួមរបស់សមាជិកទាំងអស់របស់សមាគម ជាជាងការកំណត់តម្លៃខុសៗគ្នាចំពោះជីវិតខុសៗគ្នា និងមានការ ឆ្លើយតបចំពោះតម្រូវការដែលបានលើកឡើង និងគោលដៅរបស់សហគមន៍ទាំងមូល មិន សំដៅតែអ្នកដែលមានសម្លេង អំណាច ឬ ឥទ្ធិពលឡើយ ។ សម្គាល់ៈ ទោះបីយ៉ាងណា លទ្ធភាពទទួល បានស្មើគ្នា និងការចែកចាយស្មើគ្នា ជាទូទៅមិនត្រូវបានចាត់ទុកថាមានភាពយុត្តិធម៌ឡើយ ។ យើង

ត្រូវដឹងអំពីនិយមន័យក្នុងមូលដ្ឋាន បរិបទ និង ប្រវត្តិសាស្ត្រនៃការប្រព្រឹត្ត និង ការចែកចាយដោយយុត្តិធម៌ ដើម្បីកំណត់ថា តើការចែកចាយ ឬ លទ្ធភាពទទួលបានដោយស្មើភាពវាមានលក្ខណៈយ៉ាងដូចម្ដេច?





## ៤. តម្លាភាព

តម្លាភាពមាននៅគ្រប់សណ្ឋានអាកប្បកិរិយា ។ ភាពច្បាស់លាស់ និង បើកចំហ អំពីការធ្វើអន្តរាគមន៍ និងគោលបំណងរបស់វា ការអញ្ជើញប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យចូលរួមក្នុងដំណើរការផ្តល់យោបល់ត្រឡប់ និងចែករំលែកក្តីកង្វល់របស់ពួកគេ គឺជាការពង្រឹងសណ្ឋានអាកប្បកិរិយាវិជ្ជមាន ។ ការការពារការធ្វើអន្តរាគមន៍របស់ខ្លួនពីការរិះគន់ ឬ ការទិតៀន ពីអ្នកខាងក្រៅ នាំឱ្យមានការវាយតម្លៃលើអង្គការមួយថា មិនមានការគោរព ឬ ទំនុកចិត្តពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ហើយមិនមានការទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ។ មានតែតម្លាភាពប៉ុណ្ណោះ ដែលអាចឱ្យអង្គការមួយរៀបចំអន្តរាគមន៍មួយ ដោយមានការគោរព ការទទួលខុសត្រូវ និងយុត្តិធម៌ ដូចបានកំណត់ក្នុងបរិបទមូលដ្ឋាន ។





## ការប្រើប្រាស់សណ្ឋាន

### ការរៀបចំកម្មវិធី

នៅពេលរៀបចំអន្តរាគមន៍ សូមពិចារណាលើ សកម្មភាព និង អាកប្បកិរិយា ដែលអាចជួយភ្ជាប់ការវិភាគបរិបទរបស់អ្នកទៅនឹងការរៀបចំកម្មវិធីរបស់អ្នក ។ សណ្ឋានផលជះ អាចព្យាករណ៍ទុកបាន។ ដោយសារសណ្ឋានទាំងនេះ អាចព្យាករណ៍បាន ដូច្នេះផលជះអវិជ្ជមានក៏អាចបញ្ចៀសបានដែរ ហើយអង្គការបានរៀបចំផែនការអន្តរាគមន៍ ដែលសមស្របសម្រាប់បរិបទ ។ សណ្ឋានអាកប្បកិរិយា ក៏អាចផ្តល់ឲ្យអង្គការនូវគោលការណ៍ណែនាំ សម្រាប់រៀបចំគោលនយោបាយស្តីពី របៀបទំនាក់ទំនងរវាងបុគ្គលិក និងសហគមន៍មូលដ្ឋាន ក៏ដូចជាមិត្តរួមការងាររបស់ពួកគេ ។

### ការយល់ដឹងអំពីផលជះ

នៅពេលអ្នកចាប់ផ្តើមមើលឃើញកម្មវិធីរបស់អ្នក កំពុងមានផលជះលើកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ក្នុងបរិបទមូលដ្ឋាន ហើយសណ្ឋាននេះ មានសារៈសំខាន់ក្នុងការស្វែងយល់ពី **របៀប** ដែលផលជះទាំងនោះកំពុងកើតឡើង ។ ហើយនៅពេលអ្នកដឹងពី របៀបដែលសណ្ឋានទាំងនេះដំណើរការ អ្នកនឹងអាចដឹងយ៉ាងឆាប់រហ័សថា អ្វីជាផលវិបាកនៃផលជះវិជ្ជមាន និង ផលជះអវិជ្ជមាន ក្នុងបរិបទរបស់អ្នក ។

### ការស្វែងរកជម្រើស

សណ្ឋានផលជះ អាចផ្តល់ជា "គន្លឹះ" មួយចំនួនសម្រាប់បង្កើតជម្រើសក្នុងការកែសម្រួលកម្មវិធីរបស់អ្នក និងសម្រាប់ដោះស្រាយការផ្លាស់ប្តូរក្នុងកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ។ នៅពេលអ្នកកំណត់សណ្ឋានដែលបង្កឱ្យមានផលជះ អ្នកអាចអនុវត្ត ឬ ផ្លាស់ប្តូរសណ្ឋានទាំងនោះ និងសង្ឃឹមថាអាចកែប្រែផលជះអវិជ្ជមាន ។ អ្នកក៏អាចកំណត់ និង ពង្រឹងសណ្ឋានវិជ្ជមានបន្ថែមទៀត ។

### ការធ្វើសកម្មភាព (សណ្ឋានផលជះ)

| ប្រភេទ | ខ្លឹមសារ | លទ្ធផល/សារ |
|---|---|---|
| ការបង្រៀន | បង្រៀនអំពីការណែនាំជាមូលដ្ឋានស្តីពីសណ្ឋានផលជះ ។ ចែករំលែកបទពិសោធន៍របស់គ្រូបណ្តុះបណ្តាល។ | ការយល់ដឹងជាមូលដ្ឋានអំពីសណ្ឋានផលជះ។ |
| ការធ្វើសកម្មភាព | | |
| ការសួររកការពិត | ឱ្យសិក្ខាកាមចែករំលែករឿងអំពី សកម្មភាព ឬ សណ្ឋានអាកប្បកិរិយារបស់ពួកគេ ។ អាចអនុវត្តតាមការបង្រៀន ឬ បញ្ចូលតាម | វាអនុញ្ញាតឱ្យសិក្ខាកាមភ្ជាប់ខ្លួនឯងទៅនឹងមេរៀន ។ វាក៏គាំទ្របន្ថែមដល់មេរៀន ដែលសណ្ឋាន |

| | | |
|---|---|---|
| | សណ្ឋាននីមួយៗ។ ជាធម្មតា សិក្ខាកាមនឹងចែករំលែកបទពិសោធន៍របស់ពួកគេ ពីអ្វីដែលពួកគេបានរៀន វិធីដែលពួកគេអនុវត្តកម្មវិធី។ ពួកគេអាចមិនមានភាសា ជាក់លាក់ក្នុងការរៀបរាប់អំពីហេតុការណ៍ពីមុន។ | ទាំងនេះមានលក្ខណៈសកល និង មានជម្រើសក្នុងការធ្វើឲ្យប្រសើរឡើងនូវការរៀបចំកម្មវិធី |
| បទពិសោធន៍ | **ការវិភាគករណីសិក្សា**<br>_សម្ភារៈ_ ផ្ទាំងក្រដាសស ហ្វឺត ករណីសិក្សា<br>សូមប្រើប្រាស់ករណីសិក្សាមួយសម្រាប់ការបង្រៀន ឱ្យសិក្ខាកាមធ្វើការកំណត់សណ្ឋានផលជះ ដែលបានបង្ហាញដោយអង្គការក្នុងករណីនេះ។ (សូមមើលកំណត់សម្គាល់បង្រៀនពីករណីសិក្សា សម្រាប់ព័ត៌មានបន្ថែម)។ | ការកំណត់សណ្ឋានផលជះក្នុងបរិបទ។ |
| | ការព្យាករណ៍ពីសណ្ឋានផលជះ<br>*សម្ភារៈ ស្លាយបង្ហាញ ឬ រូបភាព ស្តីពីឧបករណ៍មិនបង្កទំនាស់*<br>១. បង្ហាញរូបភាព ឬ និទានរឿងខ្លីអំពីសណ្ឋានផលជះ ទាំងសកម្មភាព និងអាកប្បកិរិយា។<br>២. ឱ្យសិក្ខាកាមកំណត់សណ្ឋាននៅកន្លែងការងារក្នុងសាច់រឿង ឬរូបភាព។<br>៣. សួរសិក្ខាកាមតើពួកគេធ្វើការផ្លាស់ប្តូរសណ្ឋានផលជះយ៉ាងដូចម្តេច? | លំហាត់នេះ អនុញ្ញាតឱ្យសិក្ខាកាមធ្វើការកំណត់សណ្ឋានផលជះ ដោយ គ្មានការព្រួយបារម្ភណ៍ (សណ្ឋានផលជះអវិជ្ជមានក្នុងរឿង ឬ រូបភាព មិនបង្ហាញពីសកម្មភាព ឬ អាកប្បកិរិយារបស់ពួកគេ ។ វាងាយស្រួលសម្រាប់ពួកគេក្នុងការចូលរួម ហើយពួកគេអាចមានអារម្មណ៍ល្អក្នុងការវិភាគសណ្ឋានអវិជ្ជមានតាមវិធីនេះ។ |

## សណ្ឋានផលជះ និងការត្រួតពិនិត្យ វាយតម្លៃ និងការរៀនសូត្រ

- តើអ្នកអាចពិនិត្យតាមដានសណ្ឋានផលជះ ក្នុងអំឡុងពេលអនុវត្តគម្រោង បានយ៉ាងដូចម្តេច?
- តើអ្នកអាចកំណត់ថា ក្រុមមួយណាដែលមិនចូលរួមក្នុងគម្រោង?
- តើមានការគាំទ្របន្ថែម ទាំងខាងក្នុង ឬ ខាងក្រៅ ដែលអាចត្រូវការ សម្រាប់ ការយកចិត្តទុកដាក់នឹងទំនាស់? តើអ្នកអាចទទួលយកវាពីអ្នកណា? តើអ្វីខ្លះជាផលវិបាករបស់ការយកចិត្តទុកដាក់នឹងទំនាស់ នៃភាពជាដៃគូនេះ?

# ជំហានទី៦ និង ទី៧៖ ការបង្កើតជម្រើស និង ការរៀបចំកម្មវិធីឡើងវិញ

## គោលបំណង

បង្ហាញសិក្ខាកាមនូវភាពចាំបាច់នៃការធ្វើបច្ចុប្បន្នភាពផែនការកម្មវិធីរបស់ខ្លួន ដោយផ្អែកលើការវិភាគកម្មវិធីរបស់ខ្លួន ផលជះរបស់ខ្លួន និងបរិបទដែលពួកគេកំពុងធ្វើការ។ វគ្គនេះ ក៏នឹងផ្តល់ឲ្យសិក្ខាកាមផងដែរនូវកាលានុវត្តភាព ក្នុងការអនុវត្តបង្កើតនូវជម្រើស និងការរៀបចំកម្មវិធីឡើងវិញជាមួយក្រុម និងដោយមានជំនួយពីអ្នកបណ្តុះបណ្តាល។ វគ្គនេះគប្បីបង្ហាញដល់សិក្ខាកាមថា ដំណើរបង្កើតជម្រើស គឺមិនមែនធ្វើឡើងដោយស្ម័គ្រចិត្តនោះទេ។ ផ្ទុយទៅវិញ វាជាផ្នែកដ៏សំខាន់មួយនៃការយកចិត្តទុកដាក់នឹងទំនាស់។

## ខ្លឹមសារមេរៀន៖ ជម្រើស

យើងដឹងថា ការទំនាក់ទំនងរបស់កម្មវិធី និងបរិបទ គឺមិនដូចគ្នាទៅនឹងការធ្វើកិច្ចការផ្សេងៗអំពីកម្មវិធីទេ។ ដើម្បីអនុវត្តការយកចិត្តទុកដាក់នឹងទំនាស់ អ្នកត្រូវសម្របសម្រួលកម្មវិធី របស់អ្នកជាបន្តដើម្បីឲ្យសមស្របទៅតាមបរិបទដែលកំពុងផ្លាស់ប្តូរ។ បើទោះបីជាមានការរៀបចំផែនការយ៉ាងរឹងមាំយ៉ាងណាក្តី ផលជះអវិជ្ជមានដែលពុំបានព្យាករណ៍ទុកជាមុននោះ នឹងកើតឡើង។ នៅពេលដែលផលជះទាំងនោះកើតឡើង វានឹងក្លាយជាការងាររបស់អ្នកក្នុងការជ្រើសរើសជម្រើស ដែលអាចអនុវត្តបាន និងមានប្រយោជន៍ដើម្បីសម្រេចបាន**គោលដៅកម្មវិធីដូចគ្នា** ដោយពុំមានផលជះអវិជ្ជមានដោយពុំបានដឹង និងទីកន្លែងដែលអាចកើតឡើង ដោយជម្រុញផលជះវិជ្ជមាន។

ពុំមានការណែនាំសម្រាប់ការសម្របសម្រួលកម្មវិធី ដែលនឹងមានប្រសិទ្ធភាពបំផុតក្នុងបរិបទរបស់អ្នកនោះទេ។ អ្នកត្រូវប្រើប្រាស់នូវអ្វីដែលអ្នកដឹងក្នុងបរិបទនេះ អ្វីដែលអ្នកដឹងអំពីផលជះដែលអាចកើតមាន និងផលជះជាក់ស្តែង ព្រមទាំងភាពច្នៃប្រឌិតរបស់ក្រុមការងារអ្នក ក្នុងការឆ្លើយតបឲ្យបានសមស្របទៅនឹងការផ្លាស់ប្តូរក្នុងបរិបទនេះ។

ការសម្របសម្រួលកម្មវិធីទាំងនេះ នឹងមានសារៈសំខាន់តែវាមិនមានច្រើនទេ។ វាអាចគ្រាន់តែតម្រូវឲ្យមានការកែប្រែតូចមួយ ចំពោះអ្វីដែលយើងកំពុងធ្វើបានល្អរួចហើយ ដើម្បីបង្កើនផលជះវិជ្ជមាន វាអាចជាការផ្លាស់ប្តូរមួយដែលមិនសូវសំខាន់ ដែលអ្នកមិនបានពិចារណាតាមដានពីផលជះរបស់វា។ តែអ្នកត្រូវចងចាំថា ផលជះភាគច្រើនកើតឡើងពីព័ត៌មានលម្អិតនៃកម្មវិធី មិនមែនពីកម្មវិធីទាំងមូល។

ត្រង់ចំណុចនេះ អ្នកបានវិភាគរួចហើយពីកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ក្នុងបរិបទ។ អ្នកបានសិក្សាយ៉ាងហ្មត់ចត់នូវព័ត៌មានលម្អិតនៃកម្មវិធីជំនួយ និងបានស្វែងយល់ពីសណ្ឋានផលជះ។ ឥឡូវនេះ ការងាររបស់អ្នក គឺត្រូវប្រើប្រាស់ការយល់ដឹងរបស់អ្នកអំពីទំនាក់ទំនងរវាងបរិបទ និង កម្មវិធីរបស់អ្នក ដើម្បីធ្វើឲ្យកម្មវិធីរបស់អ្នកទទួលបានបានលទ្ធផលល្អច្រើនបំផុតតាមតែអាចធ្វើទៅបាន។

## ការបង្កើតជម្រើសកម្មវិធី

- ***ពិនិត្យមើល*** *កត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់* ***ជាប្រចាំសម្រាប់ការផ្លាស់ប្តូរ។*** *ត្រូវឧស្សាហ៍ពិនិត្យឡើងវិញនូវអទិភាពរបស់ កត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់ ដើម្បីធ្វើការពិនិត្យតាមដានវា ហើយនិងធ្វើការចាត់អទិភាពឡើងវិញ ប្រសិនបើចាំបាច់។*
- ***ស្វែងយល់ពីសណ្ឋានផលជះ*** *បើការផ្លាស់ប្តូរមួយត្រូវបានអង្កេតក្នុងអាទិភាពនេះ ឬបង្កឲ្យមានភាពតានតឹងចំពោះ****កត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់****នោះ សូមសួរខ្លួនអ្នកថា «ហេតុអ្វី?» តើសណ្ឋានផលជះណាមួយ ដែលបានជម្រុញឲ្យមានការផ្លាស់ប្តូរនោះ? តើព័ត៌មានលម្អិតកម្មវិធីណាមួយ ដែលទាក់ទងនឹងសណ្ឋានផលជះនេះ?*
- ***ស្វែងយល់ពីជម្រើសដើម្បីផ្លាស់ប្តូរសណ្ឋានផលជះ*** *ការធ្វើបែបនេះ ហាក់បីដូចជាងាយស្រួល តែវាមិនមែនតែងតែងាយស្រួលបែបនេះឡើយ។ ទោះជាយ៉ាងនេះក្តី បើអ្នកស្វែងយល់ថា ប្រភេទនៃផលជះអវិជ្ជមានជាក់លាក់មួយកំពុងកើតឡើង ហើយអ្នកមិនបានផ្លាស់ប្តូរសណ្ឋាន ឬដោះស្រាយសណ្ឋានអវិជ្ជមាននោះទេ អ្នកមិនបានរកឃើញនូវជម្រើសឆ្លើយតបនឹងទំនាស់ទេ។*
- ***ត្រួតពិនិត្យជម្រើសរបស់អ្នកឲ្យបានច្បាស់លាស់*** *មុនពេលធ្វើការសម្រេចចិត្តទៅលើជម្រើសណាមួយសម្រាប់យកមកអនុវត្តនោះ សូមពិចារណាម្តងទៀត អំពីកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ដើម្បីធានាបានថាអន្តរាគមន៍ ដែលនឹងត្រូវយកមកអនុវត្តនេះ នឹងមិនមានផលជះអវិជ្ជមានដោយអចេតនានោះទេ។*

## *គន្លឹះ និងភាពប៉ិនប្រសព្វដើម្បីបង្កើតជម្រើសកាន់តែងាយស្រួល*

- **ធ្វើការជាក្រុម!** ការយល់ឃើញ និងបទពិសោធន៍កាន់តែច្រើន នឹងបង្កើតបានគំនិតកាន់តែច្រើន
- **ការប្រមូលគំនិត!** បើអ្នកអាចបង្កើតតារាងនៃជម្រើសចំនួន៥០ ជម្រើស៥ក្នុងចំណោម ជម្រើសទាំង៥០នោះ នឹងក្លាយជាជម្រើសល្អក្នុងចំណោមជម្រើសទាំងនោះ ហើយអាចនឹងមានជម្រើសដែលយើងអាចអនុវត្តបាន ដោយប្រើប្រាស់ធនធានដែលយើងមាន។ ក្នុងចំណោមជម្រើសទាំងនោះ អាចមានជម្រើសមួយដែលយើងអាចអនុវត្តបានដោយងាយស្រួល។ សូមបើកចិត្តឲ្យទូលាយទទួលយកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។
- **បណ្តុះគំនិតរបស់អ្នកក្នុងបរិបទមូលដ្ឋាន៖** អ្វីដែលមានប្រសិទ្ធភាពនៅកន្លែងមួយ នឹងមិនមានប្រសិទ្ធភាពនៅកន្លែងផ្សេងទៀតឡើយ។
- **សហការជាមួយសហគមន៍មូលដ្ឋាន៖** ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដឹងពីបរិបទរបស់ខ្លួនច្រើនជាងអ្នកខាងក្រៅ។ ពួកគេនឹងដឹងច្បាស់ពីអ្វីដែលអាចមានប្រសិទ្ធភាព និងអ្វីដែលអាចនឹងគ្មានប្រសិទ្ធភាព។ សូមសាកសួរពីការយល់ឃើញរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

## ដំណើរការរបស់ឧបករណ៍មិនបង្កទំនាស់កំពុងបន្ត

ឧបករណ៍មិនបង្កទំនាស់ មិនត្រឹមតែជាឧបករណ៍មួយប៉ុណ្ណោះទេ វាជាដំណើរការជាបន្តបន្ទាប់មួយ ដែលអាចច្របាច់បញ្ចូលក្នុងការងាររបស់អង្គការ ឬ ការងាររបស់ក្រុមការងារមួយបានផងដែរ។ ដំណើរការនេះ មានលក្ខណៈដដែលៗ ហើយវាត្រូវបានអនុវត្តម្តងហើយម្តងទៀតដើម្បីឲ្យមានប្រយោជន៍

និងដើម្បីធ្វើអន្តរាគមន៍ឆ្លើយតបទំនាស់។ អ្នកត្រូវពិនិត្យតាមដានជាបន្តនូវផលជះ ធ្វើបច្ចុប្បន្នភាពការវិភាគរបស់អ្នក និងត្រួតពិនិត្យឡើងវិញនូវព័ត៌មានលម្អិតសំខាន់ៗនៃកម្មវិធីរបស់អ្នក។ ទោះជាយ៉ាងនេះក្តី ការពិនិត្យតាមដានជាប្រចាំបែបនេះ មិនចាំបាច់ក្លាយជាដំណើរការផ្លូវការមួយជានិច្ចនោះទេ ពោលគឺអ្នកនឹងអង្កេតជាធម្មតាពីការផ្លាស់ប្តូរ និងផលជះក្នុងអំឡុងពេលធ្វើសកម្មភាពប្រចាំថ្ងៃរបស់អ្នក។

ខាងក្រោមនេះ គឺជាជំហ៊ានទាំង៧ នៃដំណើរការឧបករណ៍មិនបង្កទំនាស់៖

១. ស្វែងយល់ពីបរិបទនៃទំនាស់
២. វិភាគកត្តាបែកបាក់ និងប្រភពនៃភាពតានតឹងក្នុងបរិបទ
៣. វិភាគកត្តាផ្សាភ្ជាប់ និងសមត្ថភាពមូលដ្ឋានដើម្បីរក្សាសន្តិភាពក្នុងបរិបទ
៤. ដឹងពីព័ត៌មានលម្អិតសំខាន់ៗនៃអន្តរាគមន៍របស់កម្មវិធី
៥. វិភាគផលជះរបស់អន្តរាគមន៍លើកត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់ តាមរយៈសកម្មភាព និងឥរិយាបថបុគ្គលិក
៦. បង្កើតជម្រើសរៀបចំកម្មវិធី
៧. ធ្វើការសាកល្បងជម្រើស និងរៀបចំអន្តរាគមន៍ឡើងវិញ។




បន្ទាប់ពីបញ្ចប់ជំហ៊ានទាំង៧នេះហើយ អ្នកត្រូវត្រួតពិនិត្យឡើងវិញនូវបរិបទ និងកត្តាបែកបាក់ ព្រមទាំងកត្តាផ្សាភ្ជាប់ ដើម្បីឲ្យដឹងថា *តើអន្តរាគមន៍ ដែលបានរៀបចំឡើងវិញនោះ កំពុងមានផលជះតាមការគ្រោងទុករបស់វាដែរ ឬយ៉ាងណា?*

សិក្ខាកាមនឹងបានឆ្លងកាត់ដំណើរការនេះ (អាចឆ្លងកាត់ច្រើនដង) នៅពេលមានសិក្ខាសាលានេះ។

ជំហ៊ានទាំងនេះ អាចត្រូវបានច្របាច់បញ្ចូលក្នុងការរៀបចំផែនការ ការបង្កើត និង ដំណើរការត្រួតពិនិត្យតាមដាន និង វាយតម្លៃ បន្ថែមលើការអនុវត្តកម្មវិធី និងការចូលរួមរបស់សហគមន៍។

ក្នុង**ដំណាក់កាលរៀបចំផែនការ** ក្រុមការងារអាចរៀបចំពេលវេលាសម្រាប់ការវិភាគកម្មវិធីដោយប្រើឧបករណ៍មិនបង្កទំនាស់ ជាលក្ខណៈក្រុម ឬ រៀបចំកិច្ចប្រជុំជាប្រចាំសម្រាប់បុគ្គលិក ដើម្បីពិភាក្សាពីការអង្កេតរបស់ខ្លួនចំពោះកត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ ក្នុងបរិបទ។ នេះគឺជាមធ្យោបាយមួយនៃការពិនិត្យតាមដានការផ្លាស់ប្តូរក្នុងបរិបទ។

ការពិនិត្យមើលឡើងវិញនូវបញ្ជីឈ្មោះ ព្រមទាំងការធ្វើអាទិភាព កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់ជាប្រចាំ (និងជាញឹកញាប់) មានសារៈសំខាន់បំផុតចំពោះការធានាបាននូវការយកចិត្តទុកដាក់នឹង ទំនាស់។

បើទោះជាយើងមានផលប៉ះពាល់មួយមកលើបរិបទក្តី យើងមិនមែនជាអ្នកអនុវត្តកម្មវិធីតែម្នាក់ ដែលធ្វើបែបនេះនោះទេ។ រឿងរ៉ាវនានាកំពុងកើតឡើងក្នុងបរិបទគ្រប់ពេល ហើយបើទោះជាយើងអាចនឹងមិនទទួលខុសត្រូវចំពោះការផ្លាស់ប្តូរ កត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់ក្តី យើងត្រូវទទួលខុសត្រូវចំពោះអ្វីដែលកំពុងកើតឡើងក្នុងបរិបទនេះដែរ។

អ្នកឆ្លងកាត់ដំណើរការនៃការប្រើប្រាស់ឧបករណ៍មិនបង្កទំនាស់ កាន់តែច្រើន វានឹងកាន់តែងាយស្រួលនឹងសម្រេចបាន ហើយអ្នកនឹងមើលឃើញនូវព័ត៌មានលម្អិតនៃបរិបទនេះកាន់តែច្រើន។

## សកម្មភាព

| **ប្រភេទ** | **ខ្លឹមសារ** | **លទ្ធផល/សារ** |
|---|---|---|
| ការបង្រៀន | ការបង្រៀនណែនាំស្តីពីជម្រើស។ | ការយល់ដឹងជាមូលដ្ឋានពីវិធីនិងមូលហេតុក្នុងការបង្កើតជម្រើស។ |
| ការធ្វើសកម្មភាព | | |
| ការស្វែរកការពិត | **ល្បែងជម្រើស**<br>សម្ភារៈ: ផ្ទាំងក្រដាសស ប៊ិចគូសចំណាំ ម៉ោងកំណត់ពេល (សិក្ខាកាមត្រូវការក្រដាស និងប៊ិច)<br>មានប្រភេទមួយចំនួននៃល្បែងនេះក្នុងឧបសម្ព័ន្ធសកម្មភាព។ នេះគឺជាល្បែងដែលប្រើប្រាស់កម្លាំងច្រើន ដែលមាន ភាពរហ័សរហួន និងសប្បាយ ហើយ អាចជាល្បែងជម្រុញដ៏ល្អមួយផងដែរ។<br>លើផ្ទាំងក្រដាសធំ សូមសរសេរអក្សរ ក, ខ, និង គ ឲ្យធំៗ នៅលើអង្កត់ទ្រូងមួយ។ សូមគូសសញ្ញាព្រួញពីអក្សរ ក ទៅ ខ និងពីអក្សរ ខ ទៅ គ។ សូមគូសរង្វង់ ឬគូសជាប្រអប់នៅជុំវិញអក្សរ ខ។ ប្រាប់ទៅក្រុមថា៖ «ខ្ញុំនឹងឲ្យបរិបទមួយទៅអ្នក ហើយអ្នក ត្រូវបង្កើតជម្រើសឲ្យបានច្រើនតាមដែលអាចធ្វើបានដើម្បីដោះស្រាយ*សេណារីយ៉ូ*នេះដោយផ្អែកលើព័ត៌មានដែលទទួលបាន។ អ្នកនឹងធ្វើការជាក្រុម ដែលមានគ្នាពីរនាក់ (សូមចាប់គូ មុនពេលអ្នកផ្តល់ សេណារីយ៉ូឲ្យពួកគេ)។ អ្នកស្ថិតក្នុងក្រុម ក។ មានមនុស្សឃ្លាន អាហារនៅក្នុងក្រុម ខ។ ផ្លូវធ្វើ | មានចំណុចរៀនសូត្រសំខាន់២ នៅក្នុងលំហាត់នេះ៖<br>១. ខួរក្បាលកាន់តែច្រើន បង្កើតជម្រើសកាន់តែច្រើន។ ក្រុមមួយមានគ្នាពីរនាក់ អាចបង្កើតជម្រើសបាន១៥ ហើយមនុស្សនៅក្នុងថ្នាក់ទាំងអស់ នឹងតែងតែអាចបង្កើតជម្រើសយ៉ាងហោចណាស់ច្រើនជាងនេះពីរដង។<br>២. នៅក្នុងតារាងមួយ មានជម្រើសជាច្រើន ត្រូវបានបង្កើតឡើងដោយក្រុមមួយក្នុងរយៈពេលខ្លី ដោយមានព័ត៌មានតិចតួច ជម្រើសមួយចំនួនអាចដោះស្រាយបញ្ហាបាន។ ភាគច្រើនក្រុមការងារទំនងជាលើកឡើងថា ជម្រើសទាំងអស់មិនមែនសុទ្ធតែល្អនោះទេ។ អ្នកត្រូវបញ្ជាក់ប្រាប់ពួកគេថាការបង្កើតជម្រើសល្អៗនោះមិនមែនជាផ្នែកនៃការបង្រៀននោះទេ។ ការប្រមូលគំនិតដោយគ្មានការរឹតត្បិត អាចបង្កើតភាពច្នៃប្រឌិត។ |

| ប្រភេទ | ខ្លឹមសារ | លទ្ធផល/សារ |
|---|---|---|
| | ដំណើរពី ក ទៅ គ នឹងឆ្លងកាត់តាម ខ។ សូមផ្ដល់ អាហារដល់ក្រុម គ » ផ្ដល់រយៈពេល២នាទីដើម្បីបង្កើតតារាងជម្រើសឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ បន្ទាប់ពីរយៈពេល២នាទី បានកន្លងផុតទៅឲ្យក្រុមលើកដៃរបស់ខ្លួន បើពួកគេមានជម្រើសចំនួន៥ សូមឲ្យពួកគេបន្តលើកដៃ នៅពេលអ្នកសួរពីចំនួនជម្រើសកាន់តែច្រើនឡើងៗ រហូតដល់អ្នករកឃើញក្រុមដែលមានជម្រើសច្រើនជាងគេ។ សូមឲ្យពួកគេអានជម្រើសរបស់ខ្លួន ហើយដាក់សញ្ញាសម្គាល់ជម្រើសទាំងនោះនៅលើផ្ទាំងក្រដាសធំ ដោយគូសសញ្ញាតូចមួយ ហើយដាក់សញ្ញា (✓) បន្ទាប់មកដើរជុំវិញបន្ទប់ ហើយស្នើឲ្យក្រុមផ្សេងទៀត បន្ថែមនូវជម្រើសដែលមិនទាន់បានដាក់បញ្ចូល។ នៅទីបញ្ចប់ ប្រាប់ក្រុមពីចំនួនជម្រើស ដែលពួកគេបានបង្កើតឡើងទាំងអស់គ្នា | |
| បទពិសោធន៍ | <u>សម្ភារៈ</u> ផ្ទាំងក្រដាសស និងប៊ិចគូស ចំណាំករណីសិក្សា ស្នើឲ្យសិក្ខាកាមប្រគល់ករណីសិក្សាមកវិញ ហើយស្វែងយល់ពីជម្រើស ដើម្បីកែលម្អផលជះរបស់កម្មវិធី។ (សូមមើលឯកសារបង្រៀនករណីសិក្សា)។ | ការបង្កើតជម្រើសផ្អែកលើព័ត៌មាននៃបរិបទ និងផលជះ។ |

## ការពិនិត្យតាមដាន ការវាយតម្លៃ និងរៀនសូត្រ ព្រមទាំងជម្រើស

- តើអ្វីដែល «មានប្រសិទ្ធភាពបំផុត» ក្នុងបរិបទនេះ (សម្រាប់ការអនុវត្ត ក៏ដូចជាសម្រាប់ការអនុវត្តការយកចិត្តទុកដាក់នឹងទំនាស់)?
- តើយើងគប្បីត្រូវពិនិត្យតាមដានអ្វីដែលថ្មី (កត្តាបែកបាក់/កត្តាផ្សារភ្ជាប់ថ្មីៗ សណ្ឋានផលជះថ្មីៗ) ដែរឬទេ?
- តើការពិនិត្យតាមដាននូវ កត្តាបែកបាក់/កត្តាផ្សារភ្ជាប់ ទាំងអស់ ជាកត្តាចាំបាច់ចំពោះការអនុវត្តការយកចិត្តទុកដាក់នឹងទំនាស់របស់អ្នកដែរឬទេ? បើមិនចាំបាច់ ហេតុអ្វី?


ក្របខណ្ឌឧបករណ៍មិនបង្កទំនាស់សម្រាប់ការវិភាគពីផលជះរបស់ជំនួយលើទំនាស់
បរិបទ
ជម្រើស
កត្តាបែកបាក់
គម្រោង/សកម្មភាព
កត្តាផ្សារភ្ជាប់
ជម្រើស
ប្រព័ន្ធ និង ស្ថាប័ន
ឥរិយាបថ និង សកម្មភាព
គុណតម្លៃ និង ផលប្រយោជន៍ (ខុសគ្នា)
បទពិសោធន៍ (ផ្សេងគ្នា)
និមិត្តរូប និង ព្រឹត្តិការណ៍
អ្វី?
ពេលណា?
នៅឯណា?
ដោយនរណា?
សម្រាប់នរណា?
ជាមួយនរណា?
ហេតុអ្វី
របៀបណា?
ប្រព័ន្ធ និង ស្ថាប័ន
ឥរិយាបថ និង សកម្មភាព
គុណតម្លៃ និង ផលប្រយោជន៍ (រួម)
បទពិសោធន៍ (រួម)
និមិត្តរូប និង ព្រឹត្តិការណ៍
រៀបចំ
ឡើងវិញ
សកម្មភាព &
ឥរិយាបថ
រៀបចំ
ឡើងវិញ
បញ្ជូនធនធាន
ទីផ្សារ
ចែកចាយ
ជំនួស
ទទួលស្គាល់
ការគោរព
ការទទួលខុសត្រូវ
ភាពត្រឹមត្រូវ/ស្មើភាព
តម្លាភាព
បញ្ជូនធនធាន
ទីផ្សារ
ចែកចាយ
ជំនួស
ទទួលស្គាល់

# CONTACT US


9-11, Street 476, Toul Tumpoung I, Khan Chamkamorn,
P.O 885, Phnom Penh, Cambodia

+855 (0)23 214 152

info@ccc-cambodia.org

www.ccc-cambodia.org


The Cooperation Committee for Cambodia (CCC) is a leading membership organization with nearly 170 Local and International Non-Governmental Organizations (NGOs) in Cambodia. CCC has been playing a unique role since 1990 as an enabling agent to facilitate Civil Society Organizations (CSOs) to collectively, responsibly and accountably work together for good governance, enabling environment and sustainability of CSOs in Cambodia.

Vision: Sustainable development for Cambodia.

Mission: As a membership based organization, CCC works in inclusive partnerships for good governance, enabling environment and sustainability of civil society organizations in Cambodia.

Goal: A strong and capable civil society, cooperating and responsive to Cambodia's development challenges .

Values:

- Integrity
- Responsiveness
- Quality
- Cooperation
- Inclusiveness